UNITED NATIONS CONFERENCE ON TRADE AND DEVELOPMENT

UNCTAD

# ការធ្វើចំណាត់ថ្នាក់នៃវិធានការមិនមែនពន្ធ

## បច្ចុប្បន្នភាពត្រឹម ខែកុម្ភៈ ឆ្នាំ២០១២




UNITED NATIONS

New York and Geneva, 2015

UNCTAD NTM-KH.indd 1 11/23/2021 3:26:04 PM

**បោះពុម្ពលើកទី១**

ចំនួន ១៥០ ក្បាល

**រៀបចំ និងបោះពុម្ពដោយ**

លេខាធិការដ្ឋាននិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម និង
គណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ
នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ឧបត្ថម្ភគាំទ្រការបកប្រែ និងបោះពុម្ពដោយ**

គម្រោងគាំទ្រការធ្វើសមាហរណកម្មតំបន់អាស៊ាន ជំនួយពាក់ព័ន្ធពាណិជ្ជកម្មកម្ពុជា (ARISE Plus Cambodia)

**ដែលបានផ្ដល់ការអនុញ្ញាតដោយសហភាពអឺរ៉ុប (EU) និង**
**ក្រសួងកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សហព័ន្ធអាល្លឺម៉ង់ (BMZ)**

**ការបដិសេធ៖** ការវិភាគ លទ្ធផល និងអនុសាសន៍នៅក្នុងអត្ថបទនេះតំណាងឲ្យគំនិតរបស់អ្នកនិពន្ធ ហើយមិនមែនជាការចាំបាច់ក្នុងការបង្ហាញពីជំហររបស់ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH នោះទេ។

UNCTAD NTM-KH.indd 4 11/23/2021 3:39:28 PM

**ចំណាំ**

ការរចនា និងខ្លឹមសារនៃឯកសារនេះ មិនមានចេតនាបញ្ចេញមតិណាមួយរបស់អង្គការសហប្រជាជាតិទាក់ទងនឹងច្បាប់ នៃប្រទេស, ដែនដី, ទីក្រុង, តំបន់ ឬអាជ្ញាធរណាមួយ ឬទាក់ទងនឹងការកំណត់ព្រំដែនឡើយ។

ខ្លឹមសារ ដែលបានបោះពុម្ពផ្សាយនេះ អាចត្រូវបានដកស្រង់ ឬបោះពុម្ពឡើងវិញ ប៉ុន្តែត្រូវបានទទួលស្គាល់ និងបានចម្លងជូននូវច្បាប់បោះពុម្ពផ្សាយ ដែលមានការដកស្រង់ និងការបោះពុម្ពឡើងវិញនេះ ជូនទៅលេខាធិការដ្ឋាន UNCTAD តាមអាសយដ្ឋានដូចខាងក្រោម÷


ប្រធាន សាខាវិភាគពាណិជ្ជកម្ម

ការិយាល័យពាណិជ្ជកម្មទំនិញ និងសេវាកម្មអន្តរជាតិ

សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ

Palais Des Nations

CH-1211 Geneva, Switzerland



UNCTAD/DITC/TAB/2012/2/Rev.1

UNITED NATIONS PUBLICATION



©Copyright United Nations 2013

All rights reserved

# មាតិកា


សេចក្តីផ្តើម ....................................................................................................1

ជំពូក A ÷ វិធានការអនាម័យ និងភូតគាមអនាម័យ ....................................................7

ជំពូក B ÷ របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ......................................................15

ជំពូក C ÷ ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន និងបែបបទផ្សេងៗ ...................................20

ជំពូក D ÷ វិធានការការពារពាណិជ្ជកម្មបន្ទាន់ .......................................................21

ជំពូក E ÷ វិធានការពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណមិនស្វ័យប្រវត្តិ, កូតា, ការហាមឃាត់ និងការត្រួតពិនិត្យគុណភាព ក្រៅពីហេតុផល SPS និង TBT ..................................................26

ជំពូក F ÷ វិធានការគ្រប់គ្រងតម្លៃ រួមទាំងការបង់ពន្ធ និងថ្លៃបន្ថែមផ្សេងៗ ...........................33

ជំពូក G ÷ វិធានការហិរញ្ញវត្ថុ .........................................................................37

ជំពូក H ÷ វិធានការដែលប៉ះពាល់ដល់ការប្រកួតប្រជែង .............................................40

ជំពូក I ÷ វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម ................................................41

ជំពូក J ÷ ការដាក់កម្រិតលើការចែកចាយ ..............................................................41

ជំពូក K ÷ ការដាក់កម្រិតលើការផ្តល់សេវាកម្មក្រោយការលក់ .......................................42

ជំពូក L ÷ ការឧបត្ថម្ភធន (ដោយមិនរាប់បញ្ចូលការឧបត្ថម្ភធនលើការនាំចេញក្រោម P7) .............42

ជំពូក M ÷ ការដាក់កម្រិតលើលទ្ធកម្មរដ្ឋាភិបាល ......................................................42

ជំពូក N ÷ កម្មសិទ្ធិបញ្ញា ..............................................................................43

ជំពូក O ÷ វិធានដើមកំណើត ..........................................................................43

ជំពូក P ÷ វិធានការពាក់ព័ន្ធនឹងការនាំចេញ ...........................................................43

## សេចក្តីផ្តើម

វិធានការមិនមែនពន្ធ ជាទូទៅត្រូវបានបកស្រាយថាជាវិធានការគោលនយោបាយនានាក្រៅពីការអនុវត្តពន្ធគយធម្មតា ដែលអាចផ្តល់ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចលើពាណិជ្ជកម្មទំនិញអន្តរជាតិ, ការផ្លាស់ប្តូរបរិមាណជួញដូរ ឬ/និងតម្លៃ (UNCTAD/ DITC/ TAB/2009/3)។ ដោយសារនិយមន័យនេះមានលក្ខណៈទូលំទូលាយ ការធ្វើចំណាត់ថ្នាក់លម្អិត គឺមានសារៈសំខាន់ណាស់ ដើម្បីកំណត់ និងបែងចែកឱ្យកាន់តែច្បាស់នូវទម្រង់ផ្សេងៗគ្នា នៃវិធានការមិនមែនពន្ធ។

ការធ្វើចំណាត់ថ្នាក់វិធានការមិនពន្ធ ដែលត្រូវបានបកស្រាយក្នុងឯកសារនេះ គឺជាវគ្គិករសាស្ត្រ (Taxonomy) នៃវិធានការទាំងអស់ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិក្នុងស្ថានភាពនាពេលបច្ចុប្បន្ន។ ការធ្វើចំណាត់ថ្នាក់វិធានការមិនមែនពន្ធនេះ ត្រូវបានពិភាក្សាយ៉ាងទូលំទូលាយ និងត្រូវបានអនុម័តដោយអង្គការអន្តរជាតិមួយចំនួនដែលត្រូវបានហៅថាក្រុមពហុទីភ្នាក់ងារ (MAST) ដើម្បីគាំទ្រដល់ក្រុមការងារស្តីពីរបាំងមិនមែនពន្ធ (Group of Eminent Persons on Non-Tariff Barriers) ដែលត្រូវបានបង្កើតឡើងដោយអគ្គលេខាធិការនៃ UNCTAD ក្នុងឆ្នាំ២០០៦។ ការប្រមូលទិន្នន័យសម្រាប់ចងក្រងការធ្វើចំណាត់ថ្នាក់នៃវិធានការមិនមែនពន្ធ ត្រូវបានធ្វើឡើងចាប់ពីឆ្នាំ ២០០៧ និងបញ្ចប់ត្រឹមឆ្នាំ ២០១២។ យ៉ាងណាមិញ ការធ្វើចំណាត់ថ្នាក់នៃវិធានការមិនមែនពន្ធ គឺជាកិច្ចការដែលនៅតែបន្តវិវត្តន៍ ស្របទៅតាមភាពជាក់ស្តែងនៃតម្រូវការពាណិជ្ជកម្មអន្តរជាតិ និងការប្រមូលទិន្នន័យ។

ការធ្វើចំណាត់ថ្នាក់ រួមបញ្ចូលមានវិធានការបច្ចេកទេសនានា ដូចជាវិធានការការពារបរិស្ថាន ឬអនាម័យក៏ដូចជាវិធានការគោលនយោបាយពាណិជ្ជកម្មផ្សេងទៀត ដូចជា កូតា ការត្រួតពិនិត្យតម្លៃ ការរឹតត្បិតការនាំចេញ ឬវិធានការការពារពាណិជ្ជកម្មជាបន្ទាន់ និងវិធានការនៅពីក្រោយព្រំដែនដទៃទៀត ដូចជា ការប្រកួតប្រជែងវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម លទ្ធកម្មរដ្ឋាភិបាល ឬការរឹតត្បិតលើការចែកចាយ។

ការធ្វើចំណាត់ថ្នាក់នេះ មិនវិនិច្ឆ័យលើភាពស្របច្បាប់, ភាពគ្រប់គ្រាន់, ភាពចាំបាច់ ឬការរើសអើងនៃគោលនយោបាយអន្តរាគមន៍ក្នុងទម្រង់ណាមួយ ដែលត្រូវបានអនុវត្តសម្រាប់ពាណិជ្ជកម្មអន្តរជាតិឡើយ។ ការធ្វើចំណាត់ថ្នាក់នេះ ទទួលស្គាល់ពីអត្ថិភាព និងត្រូវបានរចនាឡើង ដើម្បីរៀបចំព័ត៌មានជាទម្រង់មូលដ្ឋានទិន្នន័យ។ ព័ត៌មានដែលមានតម្លាភាព អាចជឿទុកចិត្តបាន និងអាចប្រៀបធៀបបាន អាចជួយឱ្យអ្នកនាំចេញទូទាំងពិភពលោកទទួលបានព័ត៌មានពាក់ព័ន្ធនឹងពន្ធគយ។ តម្លាភាពនៃព័ត៌មាន គឺជាតម្រូវការចាំបាច់ ក្នុងការចរចា ដែលនាំទៅរកសុខដុមនីយកម្ម និងការទទួលស្គាល់គ្នាទៅវិញទៅមក ដែលនាំឱ្យមានការលើកកម្ពស់ពាណិជ្ជកម្ម។

UNCTAD NTM-KH.indd 1 11/23/2021 3:39:28 PM

ក្រុម MAST ដែលបានពិភាក្សា និងស្នើការធ្វើចំណាត់ថ្នាក់នេះ រួមមាន÷
អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ
មូលនិធិរូបិយវត្ថុអន្តរជាតិ
មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ
អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច
សន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ
អង្គការអភិវឌ្ឍន៍ឧស្សាហកម្ម
ធនាគារពិភពលោក
អង្គការពាណិជ្ជកម្មពិភពលោក (WTO)

ការធ្វើចំណាត់ថ្នាក់របស់ UNCTAD-MAST បង្កើតជារចនាសម្ព័ន្ធមែកធាង ដែលបែងចែកវិធានការទាំងនោះជាជំពូក អាស្រ័យលើវិសាលភាព និង/ឬការរចនា។ ជំពូកនីមួយៗ ត្រូវបានបែងចែកទៅជាអនុក្រុមតូចៗជាច្រើន ដើម្បីអនុញ្ញាតឱ្យការធ្វើចំណាត់ថ្នាក់នៃបទប្បញ្ញត្តិ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មមានភាពកាន់តែប្រសើរឡើង។ ចំណាត់ថ្នាក់វិធានការមិនមែនពន្ធ មានជំពូកចំនួន ១៦ (A ដល់ P) ហើយជំពូកនីមួយៗត្រូវបានបែងចែកជា ៣ កម្រិត (១, ២ និង ៣ ខ្ទង់, ទៅតាមចំណាត់ថ្នាក់ប្រព័ន្ធសុខដុមនីយកម្មសម្រាប់ផលិតផល).[1] ថ្វីត្បិតតែជំពូកមួយចំនួនអាចមានដល់កម្រិត ៣ ខ្ទង់នៃការបែងចែកក៏ដោយ ជំពូកភាគច្រើនគឺមានតែ ២ ខ្ទង់ប៉ុណ្ណោះ។ ជំពូកនៃការធ្វើចំណាត់ថ្នាក់ទាំងអស់ ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម។ ជំពូកទាំងអស់នោះ ឆ្លុះបញ្ចាំងអំពីតម្រូវការនានាពាក់ព័ន្ធនឹងការនាំចូល កំណត់របស់ប្រទេសនាំចូល លើកលែងតែវិធានការដែលត្រូវបានដាក់លើការនាំចេញដោយប្រទេសនាំចេញ (ជំពូក P) ។

[1]វិធានការទាំងអស់ ត្រូវបានបកស្រាយជាមួយលេខសម្គាល់ នៅក្នុងអនុក្រុមនីមួយៗ ខណៈដែលខ្ទង់ទី ៩ គឺតែងតែត្រូវបានរក្សាទុកសម្រាប់ករណីផ្សេងៗ ដែលពុំមានដាក់បញ្ចូលនៅក្នុងអនុក្រុមនោះ។

## ការធ្វើចំណាត់ថ្នាក់វិធានការមិនមែនពន្ធតាមជំពូក

| | | |
|---|---|---|
| ការនាំចូល | វិធានការបច្ចេកទេស | A វិធានការអនាម័យ និង ភូតគាមអនាម័យ<br>B វិធានការរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម<br>C ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន និងបែបបទផ្សេងៗ |
| | វិធានការមិនមែនបច្ចេកទេស | D វិធានការការពារពាណិជ្ជកម្មបន្ទាន់<br>E វិធានការពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណមិនស្វ័យប្រវត្តិ, កូតា, ការហាមឃាត់ និងការត្រួតពិនិត្យគុណភាព ក្រៅពីហេតុផល SPS និង TBS<br>F វិធានការគ្រប់គ្រងតម្លៃ រួមទាំងការបង់ពន្ធ និងសេវាបន្ថែម<br>G វិធានការហិរញ្ញវត្ថុ<br>H វិធានការដែលប៉ះពាល់ដល់ការប្រកួតប្រជែង<br>I វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម<br>J ការដាក់កម្រិតលើការចែកចាយ<br>K ការដាក់កម្រិតលើការផ្តល់សេវាកម្មក្រោយការលក់<br>L ការឧបត្ថម្ភធន (ដោយមិនរាប់បញ្ចូលការឧបត្ថម្ភធនលើការនាំចេញក្រោម P7)<br>M ការដាក់កម្រិតលើលទ្ធកម្មរដ្ឋាភិបាល<br>N កម្មសិទ្ធបញ្ញា<br>O វិធានដើមកំណើត |
| | ការនាំចេញ | P វិធានការពាក់ព័ន្ធនឹងការនាំចេញ |

ជំពូក A សំដៅលើវិធានការអនាម័យ និងភូតគាមអនាម័យ ដែលជាទូទៅត្រូវបានហៅកាត់ថា SPS។ ជំពូកនេះផ្តោតលើវិធានការពាក់ព័ន្ធនឹងការរឹតត្បិតលើសារធាតុផ្សំ ក្នុងគោលបំណងធានាសុវត្ថិភាពចំណីអាហារ ក៏ដូចជាសម្រាប់ការពារការរាលដាលនៃជំងឺ ឬសត្វល្អិត។ ជំពូក A នេះ ក៏រាប់បញ្ចូលទាំងវិធានការវាយតម្លៃលើអនុលោមភាពពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារ ដូចជាវិញ្ញាបនប័ត្រ, ការធ្វើតេស្តនិងការត្រួតពិនិត្យ, និងការធ្វើចត្តាឡីស័កផងដែរ។

ជំពូក B ផ្តោតលើវិធានការបច្ចេកទេស ដែលហៅកាត់ថា TBT ដោយសំដៅទៅលើវិធានការ ដូចជាការបិទស្លាកសញ្ញា, ស្តង់ដារបច្ចេកទេសជាក់លាក់ និងតម្រូវការគុណភាព ក៏ដូចជាវិធានការការពារបរិស្ថានដទៃទៀត។ ដូចក្នុងករណី SPS ដែរ ជំពូក B រាប់បញ្ចូលទាំងវិធានការវាយតម្លៃអនុលោមភាព ដែលពាក់ព័ន្ធនឹងតម្រូវការបច្ចេកទេស ដូចជាវិញ្ញាបនប័ត្រ, ការធ្វើតេស្ត និងការត្រួតពិនិត្យ។ ជំពូកចុងក្រោយនៅក្នុងផ្នែកវិធានការបច្ចេកទេស គឺជំពូក C ដែលធ្វើចំណាត់ថ្នាក់វិធានការពាក់ព័ន្ធនឹងការត្រួតពិនិត្យ មុនពេលដឹកជញ្ជូន និងការអនុវត្តបែបបទគយផ្សេងៗ។

ជំពូក D ផ្តោតលើវិធានការការពារពាណិជ្ជកម្មបន្ទាន់ ពោលគឺវិធានការទាំងឡាយណា ដែលត្រូវបានអនុវត្តដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃការនាំចូលលើទីផ្សារនៃប្រទេសនាំចូល សំដៅដល់ការផ្តល់ភាពអយុត្តិធម៌ចំពោះការធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយរួមបញ្ចូលការប្រឆាំងការលក់បង្ខូចតម្លៃ, ការរារាំង និងវិធានការគាំពារផ្សេងៗ។

ជំពូក E និង F គឺជាក្រុមវិធានការ "រឹង" ដែលជាទូទៅត្រូវបានប្រើក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្ម។ ជំពូក E រាប់បញ្ចូលការផ្តល់អាជ្ញាប័ណ្ណ, កូតា និងវិធានការត្រួតពិនិត្យបរិមាណផ្សេងៗ រួមទាំងកូតាអត្រាពន្ធ។ ជំពូកF រាប់បញ្ចូលវិធានការត្រួតពិនិត្យតម្លៃ ដែលត្រូវបានអនុវត្ត ដើម្បីគ្រប់គ្រង ឬប៉ះពាល់ដល់តំលៃទំនិញនាំចូល។ ឧទាហរណ៍ ដូចជា វិធានការដែលគាំទ្រដល់តម្លៃក្នុងស្រុក នៃប្រភេទទំនិញមួយចំនួន ដោយសារការឡើងចុះនៃតម្លៃទីផ្សារក្នុងស្រុក ឬអស្ថិរភាពតម្លៃទីផ្សារបរទេស ឬការកើនឡើង ឬការការពារចំណូលពន្ធ។ វិធានការនេះ រាប់បញ្ចូលវិធានការផ្សេងទៀតក្រៅពីពន្ធគយ ដែលនាំឱ្យកើនឡើងនៃតម្លៃនាំចូល ដែលមានលក្ខណៈប្រហាក់ប្រហែល (Para-tariff measures)។

ជំពូក G ផ្តោតលើវិធានការហិរញ្ញវត្ថុ សំដៅដល់វិធានការរឹតត្បិតលើការទូទាត់នៃការនាំចូល ឧទាហរណ៍ នៅពេលការនាំចូល និងតម្លៃនៃការប្តូរប្រាក់បរទេសត្រូវបានកំណត់។ ជំពូកនេះ ក៏រាប់បញ្ចូលទាំងវិធានការដែលដាក់កម្រិតលើលក្ខខណ្ឌនៃការទូទាត់ ផងដែរ។

ជំពូក H ផ្តោតលើវិធានការទាំងឡាយណាដែលប៉ះពាល់ដល់ការប្រកួតប្រជែង រួមបញ្ចូលការផ្តល់ជំនួយផ្តាច់មុខ ឬឯកសិទ្ធិពិសេស ពិសេសចំពោះក្រុមប្រតិបត្តិករសេដ្ឋកិច្ចមួយ ឬច្រើន។ ជំពូកនេះ សំដៅដល់វិធានការឯកការធិភាព ដូចជាការធ្វើពាណិជ្ជកម្មដោយរដ្ឋ, ភ្នាក់ងារនាំចូលផ្តាច់មុខ, ឬតម្រូវការធានារ៉ាប់រងឬការដឹកជញ្ជូនដោយបង្ខំ។

ជំពូក I ផ្តោតលើវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម និងវិធានការដែលរឹតត្បិតការវិនិយោគ ដោយតម្រូវឱ្យមានមាតិកាក្នុងស្រុក ឬតម្រូវការឱ្យការវិនិយោគ ចាំបាច់ត្រូវទាក់ទងនឹងការនាំចេញ ដើម្បីឱ្យមានតុល្យភាពជាមួយការនាំចូល។

ជំពូក J និង K ផ្តោតលើវិធានការនៃការចែកចាយទំនិញ និងសេវាកម្ម ក្រោយពេលនាំចូល។ វិធានការទាំងនោះត្រូវបានចាត់ទុកថាជាវិធានការមិនមែនពន្ធ ដោយសារវាអាចប៉ះពាល់ដល់ការសម្រេចចិត្តនៅពេលនាំចូល។

ជំពូក J ស្តីពីការរឹតបន្តឹងការចែកចាយ សំដៅទៅលើវិធានការរឹតត្បិតលើការចែកចាយទំនិញនាំចូលក្នុងស្រុក។ ជំពូក K ផ្តោតលើការរឹតបន្តឹងលើការផ្តល់សេវាកម្មក្រោយការលក់ ឧទាហរណ៍ការរឹតត្បិតលើការផ្តល់សេវាកម្មបន្ទាប់បន្សំ។

ជំពូកL, M, N និងO ពាក់ព័ន្ធនឹងគោលនយោបាយនៅក្រោយព្រំដែន។ ជំពូកL មានបញ្ចូលវិធានការពាក់ព័ន្ធនឹងការឧបត្ថម្ភធន ដែលប៉ះពាល់ដល់ពាណិជ្ជកម្ម។ ជំពូកM ស្តីពីវិធានការពាក់ព័ន្ធនឹងលទ្ធកម្មរដ្ឋាភិបាល ដែលដាក់អនុវត្តចំពោះអ្នកដេញថ្លៃ លើការលក់ទំនិញទៅរដ្ឋាភិបាលបរទេស។ ជំពូក N រាប់បញ្ចូលវិធានការរឹតត្បិតពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា។ ជំពូកO ស្តីពីវិធានដើមកំណើត រាប់បញ្ចូលវិធានការរឹតត្បិតលើដើមកំណើតនៃទំនិញ ឬធាតុចូលរបស់ទំនិញ។

ជំពូកP ជាជំពូកចុងក្រោយ ផ្តោតលើវិធានការនាំចេញ ដែលប្រទេសនាំចេញត្រូវអនុវត្ត ដោយរួមបញ្ចូលពន្ធនាំចេញ, កូតា និងការរឹតត្បិតលើការនាំចេញផ្សេងៗ។

ការធ្វើចំណាត់ថ្នាក់នេះ កំណត់នូវវិធានការនីមួយៗ ដោយបានធ្វើការបកស្រាយ និងផ្តល់នូវឧទាហរណ៍ល្អៗ ដែលបានកើតឡើងភាគច្រើន ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់។

ឯកសារនេះ ត្រូវបានប្រើប្រាស់ដោយ UNCTAD ដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធនឹងវិធានការមិនមែនពន្ធ នៅជុំវិញពិភពលោក និងជាផ្នែកមួយនៃឯកសារបណ្តុះបណ្តាលស្នូល ដែលត្រូវបានប្រើប្រាស់ ដើម្បីណែនាំដល់បុគ្គលដែលបំពេញកិច្ចការពាក់ព័ន្ធនឹងការប្រមូលទិន្នន័យនៅក្នុងក្របខ័ណ្ឌតម្លាភាពពាណិជ្ជកម្ម។ កម្មវិធីនេះ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០១១ ដោយ UNCTAD, ធនាគារអភិវឌ្ឍន៍អាហ្វ្រិក, មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ និងធនាគារពិភពលោក ដោយផ្តោតលើការប្រើប្រាស់របៀបនៃការធ្វើចំណាត់ថ្នាក់ និងការប្រមូលទិន្នន័យ ក្នុងគោលការណ៍ និងនីតិវិធីដូចគ្នាទូទាំងពិភពលោក ដើម្បីធានានូវសង្គតភាពនៃការរៀបចំទិន្នន័យ។ គោលបំណងនៃកម្មវិធីនេះ គឺដើម្បីផ្តល់ព័ត៌មានអំពីវិធានការពាណិជ្ជកម្ម និងចូលរួមចំណែកក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិទាំងពហុភាគីនិងតំបន់ឱ្យកាន់តែប្រសើរឡើង។ ជាចុងក្រោយ សំខាន់ជាងនេះទៅទៀត កម្មវិធីនេះ នឹងរំពឹងថាអាចជំរុញឱ្យមានការស្រាវជ្រាវថ្មីពាក់ព័ន្ធនឹងគោលនយោបាយវិធានការមិនមែនពន្ធ និងផលវិបាករបស់ថាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។

UNCTAD NTM-KH.indd 5 11/23/2021 3:39:29 PM

## A **វិធានការអនាម័យ និងភូតគាមអនាម័យ** (SPS)

គឺជាវិធានការ ដែលអនុវត្តដើម្បីការពារជីវិតមនុស្ស ឬសត្វពីហានិភ័យ កើតឡើងពីការបន្ថែមសារធាតុ, មេរោគ, ជាតិពុល ឬសរីរាង្គបង្កជំងឺនៅក្នុងអាហារ; ដើម្បីការពារជីវិតមនុស្ស ពីរុក្ខជាតិ ឬសត្វ ដែលមានជំងឺ; ដើម្បីការពារជីវិតសត្វ ឬរុក្ខជាតិពីសត្វល្អិត,ជំងឺ ឬសរីរាង្គបង្កជំងឺ; ដើម្បីការពារ ឬទប់ស្កាត់ផលប៉ះពាល់ផ្សេងៗ ពីការនាំចូល, ការបង្កើត ឬការរីករាលដាលនៃសត្វល្អិត និងដើម្បីការពារជីវៈចម្រុះ។ វិធានការទាំងនេះ ក៏រាប់បញ្ចូលវិធានការការពារសុខភាពត្រី និងសត្វព្រៃ ក៏ដូចជាព្រៃឈើ និងរុក្ខជាតិព្រៃផងដែរ។

សូមចំណាំថា វិធានការសម្រាប់ការពារបរិស្ថាន (ក្រៅពីអ្វីដែលបានកំណត់ខាងលើ), ការពារផលប្រយោជន៍អ្នកប្រើប្រាស់ ឬសម្រាប់សុខុមាលភាពសត្វ មិនស្ថិតក្រោមជំពូក SPS ទេ។

វិធានការ ដែលត្រូវបានធ្វើចំណាត់ថ្នាក់ក្រោម A១ ដល់ A៦ គឺជាបទប្បញ្ញត្តិបច្ចេកទេស ខណៈវិធានការក្រោម A ៨ គឺជានីតិវិធីវាយតម្លៃអនុលោមភាព។

### A1 ការហាមឃាត់/ការរឹតត្បិតលើការនាំចូលសម្រាប់ហេតុផល SPS

ការហាមឃាត់និង/ឬការរឹតត្បិតលើផលិតផលសម្រេចសម្រាប់នាំចូល ត្រូវបានធ្វើចំណាត់ថ្នាក់នៅក្នុងជំពូកនេះ។ ការរឹតត្បិតលើការកំណត់បរិមាណកាកសំណល់ ឬការប្រើប្រាស់សារធាតុមួយចំនួន ដែលមាននៅក្នុងផលិតផលសម្រេចត្រូវបានចាត់ថ្នាក់ក្រោម A2 ដូចខាងក្រោម។

#### A11 **ការហាមឃាត់ផ្នែកភូមិសាស្ត្របណ្តោះអាសន្នសម្រាប់ហេតុផល SPS**

ការហាមឃាត់លើការនាំចូលផលិតផល ពីប្រទេសឬតំបន់ណាមួយ ដោយសារជំងឺឆ្លង÷ វិធានការដែលបានរាប់បញ្ចូលក្នុងប្រភេទនេះ ជាធម្មតាគឺមានលក្ខណៈពិសេស និងត្រូវបានកំណត់ពេលវេលាជាក់លាក់។

***ឧទាហរណ៍÷*** *ការនាំចូលបក្សីពីតំបន់ដែលរងផលប៉ះពាល់ដោយជំងឺផ្តាសាយបក្សី ឬគោពីប្រទេសដែលប៉ះពាល់ដោយជំងឺជើង-មាត់ ត្រូវបានហាមឃាត់។*

#### A12 **ការរឹតត្បិតផ្នែកភូមិសាស្ត្រលើការទទួលបានសិទ្ធិ**

ការហាមឃាត់លើការនាំចូលផលិតផលជាក់លាក់ ដែលពីបណ្តាប្រទេស ឬតំបន់ណាមួយ ដោយសារកង្វះភស្តុតាងនៃលក្ខខណ្ឌសុវត្ថិភាពគ្រប់គ្រាន់ ដើម្បីចៀសវាងហានិភ័យនៃអនាម័យនិងភូតគាមអនាម័យ÷ ការរឹតត្បិតនេះ ត្រូវបានអនុវត្តដោយស្វ័យប្រវត្តិរហូតទាល់តែប្រទេសនោះបញ្ជាក់ពីការអនុវត្តវិធានការអនាម័យនិងភូតគាមអនាម័យសមស្រប ដើម្បីផ្តល់នូវការការពារជាក់លាក់ សំដៅប្រឆាំងនឹងគ្រោះថ្នាក់ ដែលត្រូវបានចាត់ទុកថាអាចទទួលយកបាន។

បណ្តាប្រទេស ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានដាក់ក្នុង "បញ្ជីវិជ្ជមាន"។ ការនាំចូលពីប្រទេសផ្សេងទៀត ត្រូវហាមឃាត់។ បញ្ជីនេះ អាចរាប់បញ្ចូលសហគ្រាសផលិតកម្មដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការនៅក្នុងប្រទេសដែលមានទទួលបានសិទ្ធិ។

***ឧទាហរណ៍÷*** *ការនាំចូលផលិតផលទឹកដោះគោពីបណ្ដាប្រទេសដែលមិនទាន់មានលក្ខខណ្ឌអនាម័យសមស្រប ត្រូវបានហាមឃាត់។*

**A13 វិធានការជាប្រព័ន្ធ**

គឺជាអភិក្រម ដែលរួមបញ្ចូលគ្នានូវវិធានការ SPS ពីរ ឬច្រើនលើផលិតផលតែមួយ÷ វិធានការរួមនេះ អាចត្រូវបានបញ្ចូលវិធានការ ដែលជាប់ពាក់ព័ន្ធគ្នាច្រើន ក៏ដូចជាតម្រូវការនានា ពាក់ព័ន្ធនឹងការវាយតម្លៃអនុលោមភាព ដែលត្រូវបានអនុវត្តនៅគ្រប់ដំណាក់កាលនៃផលិតកម្ម។

***ឧទាហរណ៍÷*** *កញ្ចប់វិធានការសម្រាប់ការនាំចូល រាប់បញ្ចូលវិធានការពាក់ព័ន្ធនឹងការបញ្ជាក់ពីទីតាំងផលិតជាក់លាក់, ថ្នាំសំលាប់សត្វល្អិតដែលត្រូវប្រើ, បច្ចេកទេសប្រមូលផល ក៏ដូចជាសំលាប់មេរោគក្រោយការប្រមូលផល ដោយរួមបញ្ចូលតម្រូវការត្រួតពិនិត្យនៅតាមព្រំដែន ដូចជាតម្រូវការនៃការវិភាគ និងត្រួតពិនិត្យភាពគ្រោះថ្នាក់ (HACCP )។*

**A14 ការទទួលបានការអនុញ្ញាតពិសេសសម្រាប់ហេតុផល SPS**

គឺជាវិធានការ ដែលតម្រូវឱ្យអ្នកនាំចូល ទទួលបានការអនុញ្ញាត ឬការយល់ព្រមពីអង្គភាពរដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេសគោលដៅ សម្រាប់ហេតុផល SPS÷ ដើម្បីទទួលបានការអនុញ្ញាត អ្នកនាំចូលត្រូវគោរពតាមបទប្បញ្ញត្តិពាក់ព័ន្ធ និងការវាយតម្លៃអនុលោមភាព។

***ឧទាហរណ៍÷*** *លិខិតអនុញ្ញាតនាំចូលពីក្រសួងសុខាភិបាល ត្រូវបានទាមទារ។*

**A15 តម្រូវការចុះបញ្ជីសម្រាប់អ្នកនាំចូល**

គឺជាវិធានការ ដែលតម្រូវឱ្យអ្នកនាំចូលចុះបញ្ជីមុនពេលនាំចូលផលិតផលមួយចំនួន÷ ដើម្បីចុះបញ្ជីអ្នកនាំចូល ចាំបាច់ត្រូវគោរពតាមតម្រូវការជាក់លាក់, ផ្ដល់ឯកសារ និងបង់ថ្លៃចុះឈ្មោះ។

***ឧទាហរណ៍÷*** *អ្នកនាំចូលចំណីអាហារ ត្រូវចុះបញ្ជីនៅក្រសួងសុខាភិបាល។*

**A19 ការហាមឃាត់/ការរឹតត្បិតការនាំចូលសម្រាប់ហេតុផល SPS ក្រៅពីវិធានការខាងលើ**

A2 ការកំណត់បរិមាណនៃសារធាតុកាកសំណល់ និងការរឹតត្បិតលើការប្រើប្រាស់សារធាតុផ្សំ

**A21 ការកំណត់បរិមាណនៃកាកសំណល់ ឬការចម្លងមេរោគដោយសារធាតុ (មិនមែនជីវសាស្ត្រ)**

គឺជាវិធានការ ដែលកំណត់បរិមាណអតិបរមានៃកាកសំណល់ (MRL) ឬការកំណត់សារធាតុដូចជា ជី, ថ្នាំសម្លាប់សត្វល្អិត និងសារធាតុគីមី និងលោហៈមួយចំនួននៅក្នុងចំណីអាហារ ដែលត្រូវបានប្រើក្នុងដំណើរការផលិតកម្ម ខុសពីគ្រឿងផ្សំ ដែលត្រូវប្រើ÷ រាប់បញ្ចូលកម្រិត non-microbiological contaminants ដែលត្រូវបានអនុញ្ញាតិ។ វិធានការពាក់ព័ន្ធនឹង microbiological contaminants ត្រូវបានធ្វើចំណាត់ថ្នាក់ក្រោម A4 ដូចខាងក្រោម។

***ឧទាហរណ៍÷*** *(ក) បរិមាណអតិបរមានៃកាកសំណល់ ត្រូវកំណត់សម្រាប់ថ្នាំសម្លាប់សត្វល្អិត, លោហៈធ្ងន់ និងសំណល់ថ្នាំពេទ្យសត្វ; (ខ) POP និងសារធាតុគីមី បង្កើតក្នុងកំឡុងពេលដំណើរការ និង (គ) សំណល់នៃឌីទ្រីយន់ពីផ្លែប៉ោម និងអាភៀន។*

### A22 ការរឹតត្បិតលើកំរិតនៃសារធាតុមួយចំនួននៅក្នុងចំណីអាហារ និងផលិតផលពាក់ព័ន្ធ

គឺជាការរឹតត្បិត ឬការហាមឃាត់លើការប្រើប្រាស់សារធាតុមួយចំនួន ដែលមាននៅក្នុងចំណីអាហារ ដោយរួមបញ្ចូលទាំងការរឹតត្បិតលើសារធាតុ ដែលមានក្នុងសម្ភារៈផ្ទុកស្បៀងអាហារ ដែលអាចផ្តល់ផលប៉ះពាល់ដល់ចំណីអាហារ។

***ឧទាហរណ៍÷*** *ក) ការរឹតត្បិតលើសារធាតុសម្រាប់ផ្តល់ពណ៌, ផ្តល់ជាតិផ្អែម និងការរក្សារទុក និង (ខ) សម្ភារៈផ្ទុកចំណីអាហារ ធ្វើពី polyvinyl chloride plastic និង vinyl chloride monome មិនត្រូវលើសពី ១ មីលីក្រាមក្នុង ១ គីឡូក្រាម។*

## A 3 ការបិទស្លាកសម្គាល់ និងតម្រូវការវេចខ្ចប់

### A 31 តម្រូវការនៃការបិទស្លាកសញ្ញា

គឺជាវិធានការ តម្រូវឱ្យបង្ហាញនូវព័ត៌មានទាក់ទងទៅនឹងសុវត្ថិភាពចំណីអាហារ ដែលគួរផ្តល់ជូនអ្នកប្រើប្រាស់÷ ការដាក់ស្លាកសញ្ញា អាចធ្វើឡើងជាការសរសេរ, បែបអេឡិចត្រូនិច ឬក្រាហ្វិចលើការវេចខ្ចប់ ឬដាច់ដោយឡែក។

***ឧទាហរណ៍÷*** *(ក) ស្លាកសញ្ញា ត្រូវបញ្ជាក់លក្ខខណ្ឌសក្សាទុក ដូចជា “៥ អង្សាជាអតិបរមា” និង (ខ) គ្រឿងផ្សំដែលមានគ្រោះថ្នាក់ ដូចជា allergens ឧទាហរណ៍ “មានផ្ទុកទឹកឃ្មុំ មិនសមស្របសម្រាប់កុមារអាយុក្រោមមួយឆ្នាំ”*។

### A32 តម្រូវការលើការដាក់សញ្ញាសំគាល់

គឺជាវិធានការ តម្រូវឱ្យបង្ហាញនូវព័ត៌មានទាក់ទងទៅនឹងសុវត្ថិភាពចំណីអាហារ ដែលត្រូវភ្ជាប់នឹងកញ្ចប់ទំនិញនៅពេលដឹកជញ្ជូន និង/ឬចែកចាយ។

***ឧទាហរណ៍÷*** *នៅខាងក្រៅកុងតឺន័រដឹកទំនិញ ត្រូវសម្គាល់ដោយការណែនាំដូចជា ទំនិញងាយខូច, ត្រូវរក្សាទុកក្នុងទូរទឹកកក ឬត្រូវការពារពីពន្លឺព្រះអាទិត្យ ។ ល។*

### A33 តម្រូវការលើការវេចខ្ចប់

គឺជាវិធានការកំណត់របៀបដែលទំនិញត្រូវបានវេចខ្ចប់ ឬការកំណត់សំភារៈវេចខ្ចប់ ដើម្បីធានាសុវត្ថិភាពចំណីអាហារ។

***ឧទាហរណ៍÷*** *ការប្រើប្រាស់ PVC សម្រាប់ការវេចខ្ចប់អាហារត្រូវបានហាមឃាត់។*

## A4 តម្រូវការអនាម័យ

គឺជាតម្រូវការពាក់ព័ន្ធនឹងគុណភាព, សមាសភាព និងសុវត្ថិភាពចំណីអាហារ ដែលជាទូទៅផ្អែកលើការអនុវត្តអនាម័យ និងការផលិតល្អ (GMPs) និងការទទួលស្គាល់វិធីសាស្ត្រវិភាគ និងគំរូ÷ តម្រូវការទាំងនោះ ត្រូវបានអនុវត្តលើផលិតផលសម្រេច (A41) ឬលើដំណើរការផលិត (A44)។

### A41 លក្ខណៈវិនិច្ឆ័យលើមីក្រូជីវសាស្ត្រនៃផលិតផលសម្រេច

គឺជាតម្រូវការលើការផ្ដល់របាយការណ៍ស្ដីពីមីក្រូសរីរាង្គ, តុកស៊ីន/សាធាតុបំលែង និងហេតុផលផ្សេងៗ ដែលជាប់ពាក់ព័ន្ធ, វិធីសាស្ត្រវិភាគក្នុងការរុករក, បង្កើត និងការកំណត់បរិមាណនៃផលិតផលសម្រេច ដូចជា÷ ការកំណត់មីក្រូជីវសាស្ត្រ (Microbiological limits) ត្រូវពិចារណាលើហានិភ័យពាក់ព័ន្ធនឹងមីក្រូជីវសាស្ត្រ និងលក្ខខណ្ឌដែលចំណីអាហារ ត្រូវបានរក្សាទុក និងប្រើប្រាស់។ ការកំណត់មីក្រូជីវសាស្ត្រ (Microbiological limits) ក៏ត្រូវផ្ដោតការយកចិត្តទុកដាក់លើការចែកចាយមិនស្មើនៃក្រូជីវសាស្ត្រក្នុងចំណីអាហារ និងភាពប្រែប្រួលក្នុងដំណើរការវិភាគផងដែរ។

***ឧទាហរណ៍÷*** *ស៊ុតរាវ គួរតែត្រូវបានគេយកទៅសម្លាប់មេរោគ ឬបំផ្លាញមីក្រូសរីរាង្គសាល់ម៉ុនណេឡាជាមុនសិន។*

### A42 ការអនុវត្តអនាម័យក្នុងអំឡុងពេលផលិត

គឺជាតម្រូវការ ដែលមានគោលបំណងផ្ដល់ការណែនាំស្ដីពីការបង្កើតនិងការអនុវត្តលក្ខណៈវិនិច្ឆ័យមីក្រូជីវសាស្ត្រសម្រាប់ចំណីអាហារនៅចំណុចណាមួយនៅក្នុងខ្សែច្រវ៉ាក់ចំណីអាហារចាប់ពីផលិតកម្មបឋមដល់ការប្រើប្រាស់ចុងក្រោយ÷ សុវត្ថិភាពចំណីអាហារត្រូវបានធានាជាចម្បងដោយការត្រួតពិនិត្យទៅលើប្រភព, ការរចនាផលិតផល និងការគ្រប់គ្រងដំណើរការ និងការអនុវត្តនូវអនាម័យល្អក្នុងកំឡុងពេលផលិតកម្ម, ការកែច្នៃ (រួមទាំងការដាក់ស្លាកសញ្ញា) ការទុកដាក់, ការចែកចាយ, ការរក្សាទុក, ការលក់, ការរៀបចំ និងការប្រើប្រាស់។

***ឧទាហរណ៍÷*** *គ្រឿងបរិក្ខារចម្រាញ់យកទឹកដោះគោ (Milking equipment) នៅលើកសិដ្ឋានគួរតែត្រូវបានសម្អាតជារៀងរាល់ថ្ងៃដោយប្រើសាប៊ូដែលបានបញ្ជាក់ច្បាស់លាស់។*

### A49 តម្រូវការអនាម័យផ្សេងទៀត ក្រៅពីវិធានការខាងលើ

A5 វិធីសាស្ត្រក្នុងការកំចាត់សត្វល្អិតក្នុងរុក្ខជាតិ និងសត្វ និងសរីរាង្គបង្កជំងឺក្នុងផលិតផលសម្រេច (ឧទាហរណ៍÷ វិធីសាស្ត្រក្រោយការប្រមូលផល)

វិធីសាស្ត្រផ្សេងៗគ្នា ដែលអាចដាក់អនុវត្តក្នុងអំឡុងពេលផលិតកម្ម ឬដំណើរការក្រោយផលិតកម្ម ដើម្បីកំចាត់សត្វល្អិតក្នុងរុក្ខជាតិ និងសត្វ និងសរីរាង្គបង្កជំងឺក្នុងផលិតផលសម្រេច។

### A51 វិធីសាស្ត្រប្រើសីតុណ្ហភាពត្រជាក់/ក្ដៅ

គឺជាតម្រូវការនៃការរក្សាសីតុណ្ហភាពត្រជាក់/ក្ដៅ ឬក្រោម/លើកម្រិតសីតុណ្ហភាពជាក់លាក់ទៅលើផលិតផល សម្រាប់រយៈពេលច្បាស់លាស់មួយ ដើម្បីសម្លាប់សត្វល្អិត នៅមុន ឬពេលទៅដល់ប្រទេសគោលដៅ។ គ្រឿងបរិក្ខារប្រើប្រាស់ជាក់លាក់នៅលើគោក ឬក្នុងកប៉ាល់ អាចត្រូវបានស្នើសុំ។ ក្នុងករណីនេះ កុងតឺន័រ ត្រូវបានតម្រូវឱ្យបំពាក់ឧបករណ៍ឱ្យបានត្រឹមត្រូវ ដើម្បីអនុវត្តនូវវិធីសាស្ត្ររក្សាសីតុណ្ហភាពត្រជាក់/ក្ដៅ និងត្រូវបានបំពាក់ដោយឧបករណ៍វាស់សីតុណ្ហភាពផងដែរ។

***ឧទាហរណ៍៖*** *ប្រភេទផ្លែឈើ ដូចជាផ្លែក្រូច ត្រូវឆ្លងកាត់វិធីសាស្ត្ររក្សាសីតុណ្ហភាពត្រជាក់ (ការសម្លាប់មេរោគ) ដើម្បីកម្ចាត់រុយដែលមានក្នុងផ្លែឈើ។*

**A52 ការដាក់វិទ្យុសកម្ម**

ជាតម្រូវការនៃការសម្លាប់ ឬធ្វើអោយបាត់បង់នូវមីក្រូសរីរាង្គ, បាក់តេរី, វីរ៉ុស ឬសត្វល្អិតដែលអាចមានវត្តមានក្នុងចំណីអាហា ដោយការប្រើថាមពលវិទ្យុសកម្ម (វិទ្យុសកម្មអ៊ីយ៉ុង)។

***ឧទាហរណ៍៖*** *បច្ចេកវិទ្យានេះ អាចត្រូវបានដាក់អោយអនុវត្តលើផលិតផលសាច់ ផ្លែឈើស្រស់ គ្រឿងទេស និងបន្លែក្រៀមផ្សំគ្រឿង។*

**A53 ការបាញ់ថ្នាំសម្លាប់សត្វល្អិត**

គឺជាដំណើការនៃការសម្លាប់សត្វល្អិត ផ្សិត ឬសរីរាង្គផ្សេងៗ ដោយផ្សែងគីមីនៅក្នុងទីកន្លែងបិទជិត ក្នុងពេលវេលាកំណត់ជាក់ស្តែង។ ការបាញ់ថ្នាំសម្លាប់សត្វល្អិត គឺជាសារធាតុគីមី ដែលត្រូវការសីតុណ្ហភាព និងសម្ពាធគ្រប់គ្រាន់នៅក្នុងឧស្ម័ន ដើម្បីសម្លាប់សរីរាង្គសត្វល្អិតបាន។

***ឧទាហរណ៍៖*** *ការប្រើប្រាស់អាស៊ីតអាសេទិច គឺជាការចាំបាច់ ក្នុងការសម្លាប់សត្វល្អិតក្រោយពេលប្រមូលផល ដើម្បីកំចាត់ផ្សិតលើផ្លែប៉េស, អាព្រីកូត និងឈែរី; និងការប្រើមេទីល ប្រូមីដ សម្រាប់សម្លាប់សត្វល្អិតលើផ្កាដែលកាត់ហើយ និងទំនិញផ្សេងទៀត។*

**A59 ការកម្ចាត់សត្វល្អិតលើរុក្ខជាតិ និងសត្វ និងសរីរាង្គបង្កជំងឺលើផលិតផលសម្រេច ក្រៅពីវិធានការខាងលើ**

A6 តម្រូវការផ្សេងទៀតលើផលិតកម្ម ឬដំណើរការក្រោយផលិតកម្ម

គឺជាតម្រូវការលើដំណើរការផលិតកម្មផ្សេងទៀត (ក្រោយ) ដែលមិនបានចាត់ថ្នាក់ខាងលើ។ វា ក៏មិនរាប់បញ្ចូលវិធានការជាក់លាក់ទាំងនោះក្រោម A២ ការកំណត់បរិមាណសំរាប់សំណល់ និងការរឹតត្បិតលើការប្រើប្រាស់សារធាតុផ្សំ (ឬប្រភេទរងរបស់វា)។

**A61 ដំណើរការលូតលាស់រុក្ខជាតិ**

គឺជាតម្រូវការលើរបៀបដែលរុក្ខជាតិ គួរតែត្រូវបានដាំដុះនៅក្នុងលក្ខខណ្ឌពាក់ព័ន្ធនឹងសីតុណ្ហភាព ពន្លឺ ចន្លោះរវាងរុក្ខជាតិ ទឹក អុកស៊ីសែន សារធាតុរ៉ែ។ល។

***ឧទាហរណ៍៖*** *កម្រិតនៃការដាំ និងចន្លោះជួរនៃរុក្ខជាតិសណ្តែក គឺត្រូវបានកំណត់ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺអុចខ្មៅលើស្លឹកឈើ។*

**A62 ដំណើរការចិញ្ចឹមសត្វ ឬការចាប់សត្វ**

គឺជាតម្រូវការលើរបៀបដែលសត្វ គួរតែត្រូវបានចិញ្ចឹម ឬចាប់ ដោយសារហេតុផលអនាម័យ និងភូតគាមអនាម័យ។

***ឧទាហរណ៍៖*** *សត្វគោ មិនគួរត្រូវបានផ្តល់នូវចំណីដែលមានផ្ទុកនូវសំណល់ពីសត្វគោ ដែលសង្ស័យមានផ្ទុកជំងឺ BSE ទេ។*

### A63 ការកែច្នៃចំណីអាហារនិងចំណីសត្វ

តម្រូវការលើរបៀបផលិតចំណីអាហារ ឬចំណីសត្វ ដែលត្រូវបំពេញលក្ខខណ្ឌអនាម័យសម្រាប់ផលិតផលសម្រេច។

***ឧទាហរណ៍÷*** *ឧបករណ៍ ឬគ្រឿងម៉ាស៊ីនថ្មីសំរាប់ដោះស្រាយ ឬកែច្នៃចំណីនៅ ឬជុំវិញគ្រឹះស្ថានដែលផលិតចំណីសត្វមិនត្រូវមានផ្ទុកប៉ូលីគ្លរលីនប៉ូលីព្យូម (PCBs) ។*

### A64 លក្ខខណ្ឌផ្ទុក និងដឹកជញ្ជូន

តម្រូវការលើលក្ខខណ្ឌជាក់លាក់ សម្រាប់ការរក្សាទុកនិង/ឬដឹកជញ្ជូនចំណីអាហារ និងចំណីរុក្ខជាតិនិងសត្វ។

***ឧទាហរណ៍÷*** *គ្រឿងឧបភោគបរិភោគមួយចំនួនគួរទុកនៅកន្លែងស្ងួត ឬនៅក្រោមសីតុណ្ហភាពជាក់លាក់មួយ។*

### A69 តម្រូវការផ្សេងទៀតលើផលិតកម្ម ឬដំណើរការក្រោយផលិតកម្ម ក្រៅពីវិធានការខាងលើ

## A8 ការវាយតម្លៃអនុលោមភាពទាក់ទងនឹងអនាម័យនិងភូតគាមអនាម័យ

តម្រូវការសម្រាប់ការផ្ទៀងផ្ទាត់ថាលក្ខខណ្ឌអនាម័យនិងភូតគាមអនាម័យដែលបានផ្តល់ឱ្យ ត្រូវបានបំពេញ។ វាអាចសម្រេចបានដោយ ទម្រង់មួយ ឬរួមបញ្ចូលគ្នានៃការត្រួតពិនិត្យ និងនីតិវិធីអនុម័ត រួមទាំងនីតិវិធីសម្រាប់ការយកគំរូ, ការធ្វើតេស្ត, និងការត្រួតពិនិត្យ; ការវាយតម្លៃ, ការផ្ទៀងផ្ទាត់, និងការធានានៃអនុលោមភាព; ការទទួលស្គាល់ និងការយល់ព្រម ។ ល។

### A81 តម្រូវការចុះបញ្ជីផលិតផល

គឺជាតម្រូវការចុះបញ្ជីផលិតផលនៅក្នុងប្រទេសនាំចូល។

***ឧទាហរណ៍÷*** *តម្រូវការ និងការណែនាំសម្រាប់ការចុះបញ្ជីថ្នាំសម្លាប់សត្វល្អិត និងសមាសធាតុរបស់វា ឧទាហរណ៍ សម្រាប់ដំណាំតូចៗ/ការប្រើប្រាស់តូចតាច។ វិធានការនេះ អាចរាប់បញ្ចូលទាំងបទប្បញ្ញត្តិដែលពិពណ៌នាអំពីប្រភេទនៃផលិតផលគ្រប់គ្រងសត្វល្អិត ដែលត្រូវបានលើកលែងពីការចុះបញ្ជី និងនីតិវិធីលម្អិតនៃដំណើរការចុះបញ្ជី រួមទាំងបទប្បញ្ញត្តិទាក់ទងនឹងការចែកចាយ, ការនាំចូល, ការប្រមូលគំរូ, និងការឃាត់ទុក។*

### A82 តម្រូវការធ្វើតេស្ត

គឺជាតម្រូវការសម្រាប់ផលិតផល ដែលត្រូវធ្វើតេស្ត ដូចជា MRL÷ វិធានការនេះ រាប់បញ្ចូលទាំងករណី ដែលតម្រូវឱ្យមានគំរូ។

***ឧទាហរណ៍÷*** *ការធ្វើតេស្តលើគំរូ នៃការនាំចូលផ្លែក្រូច គឺតម្រូវឱ្យមានការត្រួតពិនិត្យលើកម្រិតអតិបរមានៃសំណល់ថ្នាំសម្លាប់សត្វល្អិត។*

**A83 តម្រូវការវិញ្ញាបនប័ត្រ**

វិញ្ញាបនប័ត្រនៃការអនុលោមតាមបទប្បញ្ញត្តិ ត្រូវបានទាមទារដោយប្រទេសនាំចូល ប៉ុន្តែអាចត្រូវបានចេញនៅក្នុងប្រទេសនាំចេញ ឬនាំចូល។

***ឧទាហរណ៍÷*** *វិញ្ញាបនប័ត្រនៃការអនុលោមតាមសំភារៈទាក់ទងនឹងចំណីអាហារ (កុងតឺន័រ, ក្រដាស, ប្លាស្ទិក។ល។) ត្រូវបានទាមទារ។*

**A84 តម្រូវការត្រួតពិនិត្យ**

គឺជាតម្រូវការសម្រាប់ការត្រួតពិនិត្យផលិតផលនៅក្នុងប្រទេសនាំចូល។ វាអាចត្រូវបានអនុវត្តដោយអង្គភាពសាធារណៈ ឬឯកជន។ វាស្រដៀង នឹងការធ្វើតេស្ត ប៉ុន្តែមិនរាប់បញ្ចូលការធ្វើតេស្តមន្ទីរពិសោធន៍ទេ។

***ឧទាហរណ៍÷*** *សត្វ ឬបំណែកនៃរុក្ខជាតិ ត្រូវតែត្រួតពិនិត្យមុនពេលអនុញ្ញាតឱ្យនាំចូល។*

**A85 តម្រូវការតាមដាន**

គឺជាតម្រូវការបង្ហាញព័ត៌មាន ដើម្បីតាមដានផលិតផលចាប់ពីដំណាក់កាលនៃការផលិត, ការកែច្នៃ, និងការចែកចាយ។

**A851 ដើមកំណើតនៃវត្ថុធាតុដើម និងផ្នែកផ្សេងៗ**

ការលាតត្រដាងព័ត៌មាន អំពីដើមកំណើតនៃវត្ថុធាតុដើម និងផ្នែកដែលត្រូវបានប្រើនៅក្នុងផលិតផលសម្រេច។

***ឧទាហរណ៍÷*** *ចំពោះបន្លែ ការបង្ហាញព័ត៌មានអំពីទីតាំងនៃកសិដ្ឋាន, ឈ្មោះរបស់កសិករ ឬជីដែលបានប្រើ អាចត្រូវបានទាមទារ។*

**A852 ប្រវត្តិដំណើរការ**

ការបង្ហាញព័ត៌មានអំពីគ្រប់ដំណាក់កាលនៃផលិតកម្ម÷ អាចរាប់បញ្ចូលទីតាំង, វិធីសាស្ត្រនៃការផលិតនិង/ ឬឧបករណ៍ និងសំភារៈប្រើប្រាស់។

***ឧទាហរណ៍÷*** *ចំពោះផលិតផលសាច់ ការបង្ហាញព័ត៌មានអំពីទីតាំងសត្តឃាត ក៏ដូចជារោងចក្រកែច្នៃចំណីអាហារអាចត្រូវបានទាមទារ។*

**A853 ការចែកចាយ និងទីតាំងផលិតផលក្រោយពេលចែកចាយ**

ការបង្ហាញព័ត៌មានអំពីពេលវេលា និងរបៀបដែលទំនិញត្រូវបានចែកចាយតាំងពីពេលបញ្ជូនដល់អ្នកចែកចាយរហូតដល់អ្នកប្រើប្រាស់ចុងក្រោយ។

***ឧទាហរណ៍÷*** *ចំពោះអង្ករ ការបង្ហាញព័ត៌មានអំពីទីតាំងនៃកន្លែងផ្ទុកបណ្តោះអាសន្ន អាចត្រូវបានទាមទារ។*

**A859 តម្រូវការតាមដាន ក្រៅពីវិធានការខាងលើ**

**A86 តម្រូវការចត្តាឡីស័ក**

តម្រូវការនៃការឃុំឃាំង ឬដាក់ដោយឡែកសត្វ, រុក្ខជាតិ ឬផលិតផលពាក់ព័ន្ធ នៅពេលមកដល់កំពង់ផែ រឺព្រំដែន ក្នុងរយៈពេលកំណត់មួយ ដើម្បីបង្ការការរីករាលដាលនៃជំងឺឆ្លង ឬការបំពុល។

***ឧទាហរណ៍÷*** *សត្វឆ្កែ ត្រូវតែដាក់ឱ្យនៅដាច់ដោយឡែកក្នុងរយៈពេលពីរសប្តាហ៍មុនត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងទឹកដី។ រុក្ខជាតិ ត្រូវដាក់ដាច់ដោយឡែក ដើម្បីការពារការរាលដាលនៃសរីរាង្គបង្កគ្រោះថ្នាក់។*

**A89 ការវាយតម្លៃអនុលោមភាពទាក់ទងនឹងអនាម័យនិងភូតគាមអនាម័យ ក្រៅពីវិធានការខាងលើ**

**A9 វិធានការអនាម័យ និងភូតគាមអនាម័យ ក្រៅពីវិធានការខាងលើ**

## B **របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម**

វិធានការនេះ សំដៅលើបទប្បញ្ញត្តិ និងនីតិវិធីបច្ចេកទេស សម្រាប់វាយតម្លៃការអនុលោមតាមបទប្បញ្ញត្តិ និងបទដ្ឋានបច្ចេកទេសនានា ដោយមិនរាប់បញ្ចូលវិធានការ ក្រោមកិច្ចព្រមព្រៀងអនាម័យនិងភូតគាមអនាម័យ។

បទប្បញ្ញត្តិបច្ចេកទេស គឺជាឯកសារដែលកំណត់លក្ខណៈផលិតផល ឬទាក់ទងនឹងដំណើរការរបស់ផលិតផល និងវិធីផលិត រួមមាន បទប្បញ្ញត្តិរដ្ឋបាល ដែលចាំបាច់។ វាក៏អាចរួមបញ្ចូលពាក្យបច្ចេកទេស, និមិត្តសញ្ញា, ការវេចខ្ចប់, ការសម្គាល់, ឬតម្រូវការការដាក់ស្លាក ដែលត្រូវអនុវត្តចំពោះផលិតផល, ដំណើរការ ឬវិធីសាស្រ្តផលិតកម្ម។ នីតិវិធីវាយតម្លៃអនុលោមភាព គឺជានីតិវិធី ដែលត្រូវបានប្រើដោយផ្ទាល់ ឬដោយប្រយោល ដើម្បីកំណត់ថាតម្រូវការពាក់ព័ន្ធនៅក្នុងបទប្បញ្ញត្តិ ឬបទដ្ឋានបច្ចេកទេស ត្រូវបានបំពេញ; វាអាចរាប់បញ្ចូលទាំងនីតិវិធីសម្រាប់ការធ្វើគំរូ, ការធ្វើតេស្ត និងការត្រួតពិនិត្យ, ការវាយតម្លៃ, ការផ្ទៀងផ្ទាត់, និងការធានាអនុលោមភាព, ការចុះបញ្ជី, ការទទួលស្គាល់ និងការអនុម័ត ក៏ដូចជាធាតុបន្សំពាក់ព័ន្ធ។

វិធានការដែលចាត់ថ្នាក់ក្រោម B1 ដល់ B7 គឺជាបទប្បញ្ញត្តិបច្ចេកទេស ខណៈពេលដែលវិធានការ មាននៅក្រោម B8 គឺជានីតិវិធីវាយតម្លៃអនុលោមភាព។ ក្នុងចំណោមបទប្បញ្ញត្តិបច្ចេកទេស បទប្បញ្ញត្តិណាដែលមាននៅក្រោម B4 ទាក់ទងនឹងដំណើរការផលិតកម្ម រីឯបទប្បញ្ញត្តិផ្សេងទៀត ត្រូវបានអនុវត្តដោយផ្ទាល់ទៅលើផលិតផល។

### B1 ការហាមឃាត់/ការរឹតត្បិតលើការនាំចូលសម្រាប់គោលបំណងដែលមានចែងក្នុងកិច្ចព្រមព្រៀងរបាំងបច្ចេកទេសពាណិជ្ជកម្ម

ការហាមឃាត់/ការរឹតត្បិតបែបនេះ អាចត្រូវបានបង្កើតឡើងសម្រាប់ហេតុផលដែលពាក់ព័ន្ធនឹងតម្រូវការសន្តិសុខជាតិ ការការពារការឆបោក ការការពារសុខភាព ឬសុវត្ថិភាពមនុស្ស សត្វ រុក្ខជាតិ ឬបរិស្ថាន។ ការរឹតត្បិតលើការកំណត់បរិមាណសំណល់ ឬការប្រើប្រាស់សារធាតុមួយចំនួន ដែលមាននៅក្នុងផលិតផលសម្រេច ត្រូវបានចាត់ថ្នាក់នៅក្រោម B2 ខាងក្រោម។

**B11 ការហាមឃាត់ដោយហេតុផលរបាំងបច្ចេកទេសពាណិជ្ជកម្ម**

ការហាមឃាត់ការនាំចូលសម្រាប់ហេតុផលដែលមានចែងក្នុង B1។

***ឧទាហរណ៍÷*** *ការនាំចូលសារធាតុគ្រោះថ្នាក់ ត្រូវបានហាមឃាត់ រាប់បញ្ចូលទាំង វិសេវត្ថុ, សារធាតុគីមីពុលមួយចំនួន ដែលស្ថិតក្រោមអនុសញ្ញាបាសែល Basel Convention ដូចជា÷ ថ្នាំបាញ់ដែលមានផ្ទុកសារធាតុ CFCs, a range of HCFCs and BFCs, halons, methyl chloroform and carbon tetrachloride។*

**B14 តម្រូវការស្នើសុំការអនុញ្ញាតពីអាជ្ញាធរសម្រាប់ហេតុផល TBT**

គឺជាតម្រូវការ ដែលអ្នកនាំចូល ត្រូវស្នើសុំការអនុញ្ញាត, ឬការយល់ព្រមពីអាជ្ញាធរ ឬភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេសគោលដៅ សម្រាប់ហេតុផលដូចជាសន្តិសុខជាតិ, ការការពារបរិស្ថាន។ល។

***ឧទាហរណ៍÷*** *ការនាំចូលត្រូវតែមានការទទួលបាននូវការអនុញ្ញាតពីអាជ្ញាធរសម្រាប់ការនាំចូលថ្នាំ, កាកសំណល់និងអេតចាយ, និងអាវុធ ជាដើម។*

**B15 តម្រូវការចុះបញ្ជីសម្រាប់អ្នកនាំចូលសម្រាប់ហេតុផល TBT**

តម្រូវការ ដែលអ្នកនាំចូល ត្រូវស្នើសុំចុះបញ្ជី ដើម្បីនាំចូលផលិតផលមួយចំនួន។ ដើម្បីចុះឈ្មោះអ្នកនាំចូល ត្រូវបំពេញតាមតម្រូវការជាក់លាក់, ឯកសារ, និងបង់ថ្លៃចុះបញ្ជី។ វាក៏រួមបញ្ចូលទាំងករណីដែលទាមទារការចុះបញ្ជីសហគ្រាស សម្រាប់ផលិតផលិតផលមួយចំនួនផងដែរ។

***ឧទាហរណ៍÷*** *អ្នកនាំចូលផលិតផលគ្រោះថ្នាក់ ដូចជាថ្នាំពេទ្យ, គ្រឿងផ្ទុះអាវុធ, ជាតិអាល់កុល, បារី, ម៉ាស៊ីនហ្គេម ជាដើម អាចនឹងតម្រូវអោយចុះបញ្ជីក្នុងប្រទេសនាំចូល។*

**B19 ការហាមឃាត់/ការរឹតត្បិតលើការនាំចូលសម្រាប់គោលបំណងដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ក្រៅពីវិធានការខាងលើ**

B2 ការកំណត់បរិមាណលើកាកសំណល់ និងការប្រើប្រាស់សារធាតុផ្សំ

**B21 ការកំណត់បរិមាណលើកាកសំណល់ដែលអាចចម្លងរោគ ដោយសារធាតុផ្សំណាមួយ**

វិធានការ ដែលកំរិតអតិបរិមានៃបរិមាណសារធាតុផ្សំ ដែលត្រូវបានប្រើក្នុងអំឡុងពេលផលិតកម្ម ប៉ុន្តែមិនមែនជាគ្រឿងផ្សំដែលបានគ្រោងទុក។

***ឧទាហរណ៍÷*** *កំរិតអំបិលនៅក្នុងស៊ីម៉ង់ត៍ ឬកំរិតស្ពាន់ធ័រនៅក្នុងប្រេងសាំង ត្រូវតែទាបជាងចំនួនដែលបានបញ្ជាក់។*

**B22 ការកំរិតលើការប្រើប្រាស់សារធាតុមួយចំនួន**

ការដាក់កំរិតលើការប្រើប្រាស់សារធាតុមួយចំនួនជាសមាសធាតុ ឬសម្ភារៈ ដើម្បីចៀសវាងហានិភ័យដែលកើតឡើងពីការប្រើប្រាស់សារធាតុទាំងនោះ។

***ឧទាហរណ៍÷*** *(ក) ការកំរិតលើការប្រើប្រាស់សារធាតុរំលាយក្នុងថ្នាំលាប (ខ) កំរិតអតិបរិមានៃសំណ ដែលត្រូវបានអនុញ្ញាតក្នុងថ្នាំលាប។*

B3 ការដាក់ស្លាកសញ្ញា, ការសម្គាល់ និងតម្រូវការវេចខ្ចប់

**B31 តម្រូវការដាក់ស្លាកសញ្ញា**

វិធានការកំណត់ប្រភេទ ពណ៌ និងទំហំនៃការបោះពុម្ពលើកញ្ចប់ និងស្លាកសញ្ញា និងការកំណត់ព័ត៌មានដែលគួរផ្តល់ជូនអ្នកប្រើប្រាស់។ ការដាក់ស្លាកសញ្ញា គឺជាការទំនាក់ទំនងដោយអក្សរ, អេឡិចត្រូនិច ឬក្រាហ្វិចលើការវេចខ្ចប់ ឬនៅលើផ្លាកដាច់ដោយឡែក ប៉ុន្តែមានជាប់ទាក់ទង ឬនៅលើផលិតផលនោះ។ វាអាចរួមបញ្ចូល តម្រូវការនានាលើភាសាផ្លូវការ ដែលត្រូវប្រើ ក៏ដូចជាព័ត៌មានបច្ចេកទេសស្តីពីផលិតផលដូចជាតង់ស្យុង, សមាសធាតុ, ការណែនាំស្តីពីការប្រើប្រាស់, សុវត្ថិភាព, និងដំបូន្មានសុវត្ថិភាព។

***ឧទាហរណ៍÷*** *ទូទឹកកកត្រូវតែដាក់ស្លាកសញ្ញា ដែលបង្ហាញពីទំហំ ទំងន់ និងកំរិតការប្រើប្រាស់អគ្គិសនី។*

**B32 តម្រូវការលើការដាក់សញ្ញាសំគាល់**

វិធានការកំណត់ព័ត៌មានសម្រាប់ការដឹកជញ្ជូន និងទំនៀមទម្លាប់ ដែលការដឹកជញ្ជូន/ចែកចាយ នៃកញ្ចប់ទំនិញត្រូវអនុវត្ត។

***ឧទាហរណ៍÷*** *លក្ខខណ្ឌនៃការទុកដាក់ ឬការផ្ទុក តាមប្រភេទផលិតផល ដែលជាធម្មតាមានសញ្ញាដូចជា “FRAGILE” ឬ “SIDE UP” ត្រូវតែសម្គាល់លើឡានដឹកទំនិញ។*

**B33 តម្រូវការវេចខ្ចប់**

វិធានការ កំណត់របៀបដែលទំនិញត្រូវតែ ឬមិនអាចវេចខ្ចប់ និងកំណត់សំភារៈវេចខ្ចប់ដែលត្រូវប្រើ។

***ឧទាហរណ៍÷*** *ឡាំង ឬកញ្ចប់ពិសេស ចាំបាច់ត្រូវប្រើសម្រាប់ការពារផលិតផលងាយខូចខាត។*

B4 តម្រូវការផលិតកម្ម ឬក្រោយផលិតកម្ម

**B41 បទប្បញ្ញត្តិរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មស្តីពីដំណើរការផលិតកម្ម**

តម្រូវការលើដំណើរការផលិតកម្ម ដែលមិនត្រូវបានចាត់ថ្នាក់ក្រោមវិធានការអនាម័យនិងភូតគាមអាម័យខាងលើ។ វា ក៏មិនរាប់បញ្ចូលវិធានការជាក់លាក់ ដែលស្ថិតនៅក្រោម B2÷ ការកំណត់បរិមាណសំណល់ និងការរឹតត្បិតលើការប្រើប្រាស់សារធាតុផ្សំ (ឬប្រភេទរងរបស់វា)។

***ឧទាហរណ៍÷*** *ការប្រើប្រាស់ឧបករណ៍ ដែលមិនប៉ះពាល់ដល់បរិស្ថាន គឺចាំបាច់។*

**B42 បទប្បញ្ញត្តិរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្មស្តីពីការដឹកជញ្ជូន និងការរក្សាទុក**

គឺជាតម្រូវការលើលក្ខខណ្ឌជាក់លាក់ សម្រាប់ការរក្សាទុក និងដឹកជញ្ជូនផលិតផល។

***ឧទាហរណ៍÷*** *ថ្នាំពេទ្យ គួរទុកក្រោមសីតុណ្ហភាពកំណត់។*

**B49 តម្រូវការផលិតកម្ម ឬក្រោយផលិតកម្ម ក្រៅពីវិធានការខាងលើ**

B6 តម្រូវការអត្តសញ្ញាណផលិតផល

លក្ខខណ្ឌ ដែលត្រូវបំពេញដើម្បីកំណត់ផលិតផលជាក់លាក់មួយ (រួមទាំងស្លាកជីវសាស្ត្រ ឬសរីរាង្គ)។

***ឧទាហរណ៍៖*** *ដើម្បីឱ្យផលិតផលត្រូវបានកំណត់ថាជាសូកូឡា វាត្រូវតែមានកម្រិតកាការជាអប្បបរមាចំនួន ៣០ ភាគរយ។*

B7 តម្រូវការគុណភាព ឬផលិតផល

លក្ខខណ្ឌ ដែលត្រូវបំពេញពាក់ព័ន្ធនឹងគុណភាព (ឧ. ភាពធន់, ភាពរឹង) ឬគុណភាព(ឧ. គ្រឿងផ្សំដែលបានកំណត់)។

***ឧទាហរណ៍៖*** *ទ្វារ ត្រូវតែធន់នឹងសីតុណ្ហភាពខ្ពស់ក្នុងកំរិតអប្បបរមាជាក់លាក់មួយ។*

B8 ការវាយតម្លៃអនុលោមភាពទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម

តម្រូវការសម្រាប់ការផ្ទៀងផ្ទាត់ថា តម្រូវការរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ដែលបានផ្តល់ឱ្យត្រូវបានឆ្លើយតប៖ នេះ អាចត្រូវអនុវត្តដោយទម្រង់បែបបទមួយ ឬរួមគ្នានៃនីតិវិធីត្រួតពិនិត្យ និងអនុម័ត រួមបញ្ចូលទាំងនីតិវិធីសម្រាប់ការយកគំរូ, ការធ្វើតេស្ត និងការត្រួតពិនិត្យ, ការវាយតម្លៃ, ការផ្ទៀងផ្ទាត់និងការធានាអនុលោមភាព, ការទទួលស្គាល់ និងការអនុម័ត។

**B81 តម្រូវការចុះបញ្ជីផលិតផល**

គឺជាតម្រូវការចុះបញ្ជីផលិតផលនៅក្នុងប្រទេសនាំចូល។

***ឧទាហរណ៍៖*** *មានតែថ្នាំដែលបានចុះបញ្ជី និងថ្នាំពេទ្យប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យនាំចូល។*

**B82 តម្រូវការតេស្តសាកល្បង**

គឺជាតម្រូវការលើការធ្វើតេស្តសម្រាប់ផលិតផល ដើម្បីពិនិត្យលើគុណភាព រួមបញ្ចូលទាំងតម្រូវការគំរូ។

***ឧទាហរណ៍៖*** *ការធ្វើតេស្តលើគំរូនៃការនាំចូលយានយន្តត្រូវបានទាមទារ ដើម្បីអនុលោមតាមតម្រូវការសុវត្ថិភាព និងឧបករណ៍របស់វា។ល។*

**B83 តម្រូវការវិញ្ញាបនប័ត្រ**

វិញ្ញាបនប័ត្រនៃការអនុលោមតាមបទប្បញ្ញត្តិដែលបានផ្តល់ឱ្យ៖ តម្រូវដោយប្រទេសនាំចូល ប៉ុន្តែអាចត្រូវបានចេញនៅក្នុងប្រទេសនាំចេញ ឬប្រទេសនាំចូល។

***ឧទាហរណ៍៖*** *វិញ្ញាបនប័ត្រនៃការអនុលោមសម្រាប់ផលិតផលអគ្គិសនី ត្រូវបានទាមទារ។*

**B84 តម្រូវការត្រួតពិនិត្យ**

តម្រូវការសម្រាប់ការត្រួតពិនិត្យផលិតផលនៅក្នុងប្រទេសនាំចូលអាចត្រូវបានអនុវត្ត ដោយអង្គភាពសាធារណៈ ឬឯកជន។ វាស្រដៀងនឹងការធ្វើតេស្ត ប៉ុន្តែមិនរាប់បញ្ចូលការធ្វើតេស្តមន្ទីរពិសោធន៍ទេ។

***ឧទាហរណ៍៖*** *ការនាំចូលវាយនភ័ណ្ឌ និងសម្លៀកបំពាក់ត្រូវតែត្រួតពិនិត្យទំហំ និងវត្ថុធាតុដើមដែលត្រូវប្រើមុននាំចូល។*

**B85 តម្រូវការលើព័ត៌មាននៃផលិតផល**

តម្រូវការបង្ហាញព័ត៌មាននៃផលិតផល ចាប់តាំងពីដំណាក់កាលនៃការផលិត, ការកែច្នៃ និងការចែកចាយ។

**B851 ដើមកំណើតនៃវត្ថុធាតុដើម និងផ្នែកផ្សេងៗ**

ការបង្ហាញព័ត៌មានអំពីដើមកំណើតនៃវត្ថុធាតុដើម និងផ្នែកដែលត្រូវបានប្រើនៅក្នុងផលិតផលសម្រេច។

***ឧទាហរណ៍÷*** *ក្រុមហ៊ុនផលិតរថយន្ត ត្រូវតែរក្សាទុកនូវកំណត់ត្រាដើមនៃសំបកកង់ដើមនៃយានយន្តនីមួយៗ។*

**B852 ប្រវត្តិដំណើរការផលិត**

ការបង្ហាញព័ត៌មាននៅគ្រប់ដំណាក់កាលនៃផលិតកម្ម អាចរាប់បញ្ចូល÷ ទីតាំង, វិធីសាស្រ្តកែច្នៃនិង/ ឬឧបករណ៍ និងសម្ភារៈប្រើប្រាស់។

***ឧទាហរណ៍÷*** *សម្រាប់ផលិតផលកាត់ដេររោមចៀម, ការបង្ហាញព័ត៌មានអំពីដើមកំណើតនៃចៀម, ទីតាំងនៃរោងចក្រវាយនភ័ណ្ឌ ក៏ដូចជាអត្តសញ្ញាណអ្នកផលិតសម្លៀកបំពាក់ អាចត្រូវបានទាមទារ។*

**B853 ការចែកចាយ និងទីតាំងផលិតផលក្រោយពេលចែកចាយ**

ការបង្ហាញព័ត៌មានអំពីពេលវេលានិង/ ឬរបៀប ដែលទំនិញត្រូវបានចែកចាយ បន្ទាប់ពីការផលិត និងមុនពេលប្រើប្រាស់ចុងក្រោយ។

***ឧទាហរណ៍÷*** *មុនពេលដាក់ផលិតផលគ្រឿងសំអាងដែលនាំចូល លក់នៅលើទីផ្សារសហភាពអឺរ៉ុប អ្នកទទួលខុសត្រូវ ចាំបាច់ត្រូវតែបញ្ជាក់អំពីទីកន្លែងតំបូង ដែលផលិតផលត្រូវបាននាំចូល, អាសយដ្ឋានរបស់ក្រុមហ៊ុនផលិត ឬអាសយដ្ឋានរបស់អ្នកនាំចូល ដល់អាជ្ញាធរមានសមត្ថកិច្ច។*

**B859 តម្រូវការតាមដាន ក្រៅពីវិធានការខាងលើ**

**B59 ការវាយតម្លៃអនុលោមភាពទាក់ទងនឹងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម ក្រៅពីវិធានការខាងលើ**

B9 វិធានការរបាំងបច្ចេកទេសពាណិជ្ជកម្ម ក្រៅពីវិធានការខាងលើ

## C ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន និងបែបបទផ្សេងទៀត

C1 ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន

ការដាក់កំហិតលើគុណភាព, បរិមាណ និងការត្រួតពិនិត្យតំលៃទំនិញមុនពេលដឹកជញ្ជូនចេញពីប្រទេសនាំចេញ ដែលកំណត់ដោយភ្នាក់ងារត្រួតពិនិត្យឯករាជ្យដែលមានការអនុញ្ញាតពីអាជ្ញាធរនៃប្រទេសនាំចូល។

***ឧទាហរណ៍÷*** *ការត្រួតពិនិត្យមុនពេលដឹកជញ្ជូនទំនិញនាំចូលដោយភាគីទីបី ដើម្បីធ្វើការផ្ទៀងផ្ទាត់ពណ៌ និងប្រភេទវត្ថុធាតុដើម ត្រូវបានតម្រូវ។*

C2 តម្រូវការលើការបញ្ជូនទំនិញដោយផ្ទាល់

តម្រូវការ លើការដឹកជញ្ជូនដោយផ្ទាល់ពីប្រទេសដើមកំណើត ដោយមិនអនុញ្ញាតឱ្យឈប់នៅប្រទេសទីបីឡើយ។

***ឧទាហរណ៍÷*** *ទំនិញនាំចូលក្រោមប្រព័ន្ធអនុគ្រោះពន្ធដូចជាGSP ត្រូវតែដឹកជញ្ជូនដោយផ្ទាល់ពីប្រទេសដើមកំណើត ដើម្បីបំពេញតាមវិធាននៃលក្ខខណ្ឌដើមកំណើត។ (ឧ. ដើម្បីធានាថាផលិតផលមិនត្រូវបានកែច្នៃ, ជំនួស ឬដំណើរការបន្តនៅក្នុងប្រទេសទីបីនៃការឆ្លងកាត់)។*

C3 តម្រូវការឆ្លងកាត់ច្រកគយជាក់លាក់ណាមួយ

តម្រូវការលើការនាំចូលឆ្លងកាត់ចំណុចត្រួតពិនិត្យដែលបានកំណត់ និង/ឬការិយាល័យគយសម្រាប់ការត្រួតពិនិត្យ, ការធ្វើតេស្ត, ។ល។

***ឧទាហរណ៍÷*** *ឧបករណ៍ចាក់ឌីវីឌី ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យនៅការិយាល័យគយដែលបានកំណត់សម្រាប់ការត្រួតពិនិត្យ។*

C4 តម្រូវការការត្រួតពិនិត្យ និងឃ្លាំមើលការនាំចូល និងវិធានការពាក់ព័ន្ធនឹងការផ្តល់អាជ្ញាប័ណ្ណស្វ័យប្រវត្តិផ្សេងទៀត

វិធានការរដ្ឋបាល លើការត្រួតពិនិត្យតម្លៃនាំចូល ឬបរិមាណផលិតផលជាក់លាក់ណាមួយ។

***ឧទាហរណ៍÷*** *ការផ្តល់អាជ្ញាប័ណ្ណនាំចូលស្វ័យប្រវត្តិ ត្រូវបានតម្រូវជានីតិវិធីរដ្ឋបាលសម្រាប់វាយនភ័ណ្ឌ និងសម្លៀកបំពាក់មុនពេលនាំចូល។*

C9 បែបបទផ្សេងទៀត ក្រៅពីវិធានការខាងលើ

## D **វិធានការការពារពាណិជ្ជកម្មបន្ទាន់**

វិធានការ ដែលអនុវត្តដើម្បីប្រឆាំងនឹងផលប៉ះពាល់អវិជ្ជមាននៃការនាំចូលក្នុងទីផ្សារនៃប្រទេសនាំចូល រួមមានវិធានការពាណិជ្ជកម្មដែលមានលក្ខណៈអយុត្តិធម៌ និងបន្ទាន់លើការបំពេញឱ្យបានគ្រប់គ្រាន់នូវតម្រូវការនីតិវិធីជាក់លាក់ណាមួយ។

D1 វិធានការប្រឆាំងការលក់បង្ខូចថ្លៃ

វិធានការ ដែលអនុវត្តនៅតាមព្រំដែនលើការនាំចូលផលិតផល។ ការនាំចូល ត្រូវបានបង្ខូចតម្លៃ ហើយបណ្តាលឱ្យប៉ះពាល់ដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតនូវផលិតផលដូចគ្នា ឬលើការនាំចេញផលិតផលនោះទៅប្រទេសទីបី។ ការបង្ខូចតម្លៃកើតឡើង នៅពេលដែលផលិតផលមួយត្រូវបានធ្វើពាណិជ្ជកម្មក្នុងប្រទេសដែលនាំចូលក្នុងតម្លៃទាបជាងតម្លៃធម្មតារបស់ខ្លួន មានន័យថា តម្លៃនាំចេញនៃផលិតផលមានតម្លៃទាបជាងតម្លៃធម្មតាក្នុងការធ្វើពាណិជ្ជកម្មសម្រាប់ផលិតផលដូចគ្នា ពេលដែលដាក់លក់ក្នុងប្រទេសនាំចេញ។ វិធានការ ប្រឆាំងការបង្ខូចថ្លៃអាចធ្វើឡើងជាទម្រង់នៃការបង់ពន្ធ ឬការដាក់ថ្លៃដោយក្រុមហ៊ុននាំចេញ។

### D11 **ការស៊ើបអង្កេតការប្រឆាំងការលក់បង្ខូចថ្លៃ**

ការស៊ើបអង្កេត ត្រូវបានធ្វើឡើងផ្អែកលើការតវ៉ាដោយឧស្សាហកម្មក្នុងស្រុក ដែលផលិតនូវផលិតផលដូចគ្នា ឬ (ក្នុងកាលៈទេសៈពិសេស) ត្រូវបានផ្តួចផ្តើមដោយអាជ្ញាធរប្រទេសនាំចូលដើម្បីតាមដានថាតើការលក់បង្ខូចតម្លៃកំពុងកើតឡើង និងធ្វើឱ្យប៉ះពាល់ដល់អ្នកផលិតក្នុងស្រុក (ឬអ្នកនាំចេញទៅប្រទេសទីបី) នៃផលិតផលដូចនោះដែរឬទេ។ វិធានការបណ្តោះអាសន្ន អាចត្រូវបានអនុវត្តក្នុងអំឡុងពេលស៊ើបអង្កេត។

***ឧទាហរណ៍÷*** *ការស៊ើបអង្កេតប្រឆាំងការទំលាក់តម្លៃត្រូវបានផ្តួចផ្តើមឡើងដោយសហភាពអ៊ឺរ៉ុបទាក់ទងនឹងការនាំចូលដែកលួសពីប្រទេស A ។*

**D12 ពន្ធប្រឆាំងការលក់បង្ខូចថ្លៃ**

ការកំណត់ពន្ធលើការនាំចូលទំនិញជាក់លាក់ ដែលមានប្រភពចេញពីដៃគូពាណិជ្ជកម្មជាក់លាក់មួយ ដើម្បីទូទាត់ការលក់បង្ខូចតម្លៃ ដែលរកឃើញថាបង្កផលប៉ះពាល់តាមរយៈការស៊ើបអង្កេត។ អត្រាពន្ធជាទូទៅមានលក្ខណៈជាក់លាក់សម្រាប់សហគ្រាស។

***ឧទាហរណ៍÷*** *ពន្ធប្រឆាំងការលក់បង្ខូចតម្លៃក្នុងចន្លោះ ៨,៥ ទៅ ៣៦,២% ត្រូវបានកំណត់លើការនាំចូលផលិតផលជីវៈម៉ាស្សូតពីប្រទេស A ។*

**D13 ការអនុវត្តការដាក់តម្លៃ**

ការអនុវត្តរបស់អ្នកនាំចេញ ដើម្បីបង្កើនថ្លៃនាំចេញរបស់ខ្លួន (ដោយមិនលើសពីការកំណត់អត្រាពន្ធប្រឆាំងការលក់បង្ខូចតម្លៃ) ដើម្បីចៀសវាងការដាក់ពន្ធប្រឆាំងការលក់បង្ខូចតម្លៃ។ តម្លៃអាចត្រូវបានចរចាសម្រាប់គោលបំណងនេះ ប៉ុន្តែអាចធ្វើបានក្រោយការសម្រេចបឋមថាការទំលាក់តម្លៃកំពុងបង្កឱ្យមានផលប៉ះពាល់។

***ឧទាហរណ៍÷*** *ករណីប្រឆាំងនឹងការទំលាក់តម្លៃពាក់ព័ន្ធនឹងផលិតផលរមៀលរៀបស្មើដែលធ្វើពីដែកថែបស៊ីលីខនធ្វើឱ្យក្រុមហ៊ុនផលិតដំឡើងថ្លៃនាំចេញ។*

D2 វិធានការប៉ះប៉ូវ

វិធានការ អនុវត្តនៅតាមព្រំដែនលើការនាំចូលផលិតផល ដើម្បីប៉ះប៉ូវលើការឧបត្ថម្ភធនដោយផ្ទាល់ឬដោយប្រយោលដោយអាជ្ញាធរនៅក្នុងប្រទេសនាំចេញ ដែលការឧបត្ថម្ភធននៃផលិតផលនោះ បង្កឱ្យមានផលប៉ះពាល់ដល់ឧស្សាហកម្មក្នុងស្រុក ដែលផលិតនូវផលិតផលដូចគ្នា។ វិធានការប៉ះប៉ូវ ត្រូវបានអនុវត្តក្នុងទម្រង់ជាការកំណត់ពន្ធប៉ះប៉ូវ ឬអនុវត្តលើក្រុមហ៊ុននាំចេញ ឬលើអាជ្ញាធរនៃប្រទេសដែលបានឧបត្ថម្ភធន។

**D21 ការស៊ើបអង្កេតលើការប៉ះប៉ូវ**

ការស៊ើបអង្កេត ត្រូវបានបានធ្វើឡើងបន្ទាប់ពីមានបណ្តឹងរបស់ឧស្សាហកម្មក្នុងស្រុកដែលផលិតនូវផលិតផលដូចគ្នា ឬ (ក្នុងកាលៈទេសៈពិសេស) ត្រូវបានផ្តួចផ្តើមដោយអាជ្ញាធរប្រទេសនាំចូលដើម្បីពិនិត្យថាតើទំនិញនាំចូលត្រូវបានទទួលការឧបត្ថម្ភធន ហើយធ្វើឱ្យប៉ះពាល់ដល់អ្នកផលិតក្នុងស្រុកឬទេ។

***ឧទាហរណ៍÷*** *ការស៊ើបអង្កេតលើការប៉ះប៉ូវ ត្រូវបានធ្វើឡើងដោយប្រទេសកាណាដាទាក់ទងនឹងការនាំចូលបំពង់ទុយោប្រេងពីប្រទេស A ។*

**D22 ពន្ធប៉ះប៉ូវ**

ជាពន្ធលើការនាំចូលផលិតផលជាក់លាក់មួយ ដើម្បីប៉ះប៉ូវឧបត្ថម្ភធនដែលផ្តល់ដោយប្រទេសនាំចេញលើផលិតកម្ម ឬការធ្វើពាណិជ្ជកម្មនៃផលិតផលនោះ នៅពេលណាដែលការស៊ើបអង្កេតបានរកឃើញថា

ការនាំចូលទំនិញដែលទទួលបានឧបត្ថម្ភធនកំពុងបង្កផលប៉ះពាល់ដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតទំនិញដូចគ្នា។

***ឧទាហរណ៍÷*** *ពន្ធប៉ះប៉ូវក្នុងអត្រា ៤៤,៧១% ត្រូវបានកំណត់ដោយប្រទេសម៉ិកស៊ិកលើការនាំចូលឧបករណ៍អេឡិចត្រូនិក dynamic random access memory (DRAM) ពីប្រទេស A ។*

**D23 ការអនុវត្តពន្ធប៉ះប៉ូវ**

ដើម្បីចៀសវាងបញ្ហានៃការអនុវត្តពន្ធប៉ះប៉ូវ ឈ្មួញនាំចេញអាចអនុវត្តពន្ធប៉ះប៉ូវដោយបង្កើនតម្លៃនាំចេញ (ដោយមិនឱ្យលើសពីចំនួនទឹកប្រាក់ឧបត្ថម្ភធន) ឬក៏អាជ្ញាធរនៃប្រទេសឧបត្ថម្ភធនអាចលុបបំបាត់ ឬកំណត់ឧបត្ថម្ភធន ឬចាត់វិធានការផ្សេងទៀតដែលទាក់ទងនឹងផលប៉ះពាល់នៃការខូចខាត។ ការចរចាលើការអនុវត្តពន្ធប៉ះប៉ូវអាចប្រព្រឹត្តទៅត្រឹមតែពេលបន្ទាប់ពីមានការសម្រេចជាបឋម ថាការនាំចូលដែលទទួលបានឧបត្ថម្ភធនគឺពិតជាបណ្ដាលឱ្យមានការរងខូចខាត។

***ឧទាហរណ៍÷*** *ការស៊ើបអង្កេតលើពន្ធប៉ះប៉ូវពាក់ព័ន្ធនឹងប្រេងដូងនិងប្រេងរុក្ខជាតិសម្រាប់ធ្វើនំមកពីប្រទេស A ដែលជាលទ្ធផល រដ្ឋាភិបាលរបស់ប្រទេស A សម្រេចអនុវត្តពន្ធប៉ះប៉ូវ ដើម្បីលុបបំបាត់ឧបត្ថម្ភធនទាំងស្រុងលើផលិតផលទាំងនោះ។*

## D3 វិធានការការពារ

### D31 វិធានការការពារទូទៅ (ពហុភាគី)

ជាវិធានការព្រំដែនបណ្ដោះអាសន្នដែលត្រូវបានអនុវត្តលើការនាំចូលផលិតផលមួយ ដើម្បីបង្ការឬផ្សះផ្សារ ការខូចខាតធ្ងន់ធ្ងរដែលបណ្ដាលមកពីការបង្កើនចំនួននៃការនាំចូលនៃផលិតផលនោះ និងដើម្បីសម្រួលដល់ការការកែតម្រូវ។ ប្រទេសមួយអាចចាត់វិធានការការពារ (ឧ. ផ្អាកការផ្ដល់សម្បទានពហុភាគីជាបណ្ដោះអាសន្ន) ទាក់ទងនឹងការនាំចូលផលិតផលពីប្រភពទាំងអស់ ដែលការស៊ើបអង្កេតបានបង្ហាញថា ការកើនឡើងនៃការនាំចូលនៃផលិតផលនោះ កំពុងបង្កឬគំរាមកំហែងឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ដែលផលិតទំនិញដូចគ្នា ឬទំនិញដែលមានការប្រកួតប្រជែងដោយផ្ទាល់។ វិធានការការពារអាចមានទម្រង់ផ្សេងៗគ្នា ដូចជា÷ ការបង្កើនពន្ធ ការរឹតត្បិតបរិមាណ និងវិធានការផ្សេងៗទៀត (*ឧទាហរណ៍÷* កូតាគិតជាអត្រាពន្ធគយ វិធានការផ្អែកលើតម្លៃ ការយកពន្ធពិសេស ។ល។)[2]

#### D311 ការស៊ើបអង្កេតលើវិធានការការពារ

ជាការស៊ើបអង្កេតមួយត្រូវបានធ្វើឡើងដោយអាជ្ញាធរនៃប្រទេសនាំចូល ដើម្បីកំណត់ថាតើទំនិញដែលស្ថិតនៅក្នុងការសង្ស័យកំពុងត្រូវបាននាំចូលក្នុងបរិមាណដែលត្រូវបានបង្កើនឡើង និងនៅក្រោមលក្ខខណ្ឌដែលបណ្ដាល ឬគំរាមកំហែងបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ផលិតករក្នុងស្រុក ឬផលិតផលដែលមានការប្រកួតប្រជែងដោយផ្ទាល់ឬទេ។

***ឧទាហរណ៍÷*** *ប្រទេស A បានផ្ដួចផ្ដើមការស៊ើបអង្កេតលើវិធានការការពារលើការនាំចូលម៉ូតូមួយចំនួន។*

### D312 កាតព្វកិច្ចចំពោះវិធានការការពារ

ជាពន្ធបណ្ដោះអាសន្នត្រូវបានអនុវត្តលើការនាំចូលផលិតផលជាក់លាក់ ដើម្បីការពារ ឬប៉ះប៉ូវការខូចខាតធ្ងន់ធ្ងរពីការកើនឡើងនៃការនាំចូល (ដូចត្រូវបានបង្កើតឡើងនៅក្នុងការស៊ើបអង្កេត) និងដើម្បីជួយសម្របសម្រួលដល់ការកែតម្រូវ។ ប្រសិនបើរយៈពេលរំពឹងទុកនៃវិធានការ គឺច្រើនជាងមួយឆ្នាំ សេរីភាវូបនីយកម្មត្រូវធ្វើជាបណ្ដើរៗ ក្នុងអំឡុងពេលនៃការអនុវត្តវិធានការ។

***ឧទាហរណ៍÷*** *កាតព្វកិច្ចចំពោះវិធានការការពាររយៈពេល ៣ ឆ្នាំ នឹងត្រូវបានអនុវត្តលើការនាំចូល Gamma Ferric Oxide ដោយគិតជាកម្រិត ១៥% ក្នុងកំឡុងឆ្នាំទីមួយ ១០% ក្នុងកំឡុងពេលឆ្នាំទីពីរ និង ៥% ក្នុងឆ្នាំទីបី។*

### D313 វិធានការការពារដោយការរឹតត្បិតលើបរិមាណ

ជាការរឹតត្បិតជាបរិមាណបណ្ដោះអាសន្នលើការនាំចូលនៃផលិតផលជាក់លាក់ដើម្បីការពារ ឬប៉ះប៉ូវការខូចខាតធ្ងន់ធ្ងរពីការកើនឡើងនៃការនាំចូល (ដូចដែលត្រូវបានបង្កើតឡើងនៅក្នុងការស៊ើបអង្កេត) និងដើម្បីសម្រួលដល់ការកែតម្រូវ។ ច្បាប់ត្រូវបានអនុវត្តទៅតាមកម្រិតនិងការបែងចែកកូតាជារួម។ ប្រសិនបើរយៈពេលរំពឹងទុកនៃវិធានការគឺច្រើនជាងមួយឆ្នាំ សេរីភាវូបនីយកម្មត្រូវធ្វើឡើងជាបណ្ដើរៗ ក្នុងអំឡុងពេលនៃការអនុវត្តវិធានការ។

***ឧទាហរណ៍÷*** *វិធានការការពារគិតជាបរិមាណ (កូតា) សម្រាប់រយៈពេល ៣ឆ្នាំ ត្រូវបានអនុវត្តលើការនាំចូលផលិតផលដែកថែប។ កម្រិតសរុបមានចំនួន ១០.០០០ តោនសម្រាប់ឆ្នាំដំបូង និង ១៥.០០០ តោននៅឆ្នាំទីពីរ និង ២២.០០០ តោន នៅឆ្នាំទីបី។*

[2] ទោះបីជាការរឹតត្បិតបរិមាណ ត្រូវបានហាមឃាត់ដោយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ក្រោមកិច្ចព្រមព្រៀងលើវិធានការការពារ ក្នុងទម្រង់នេះ វិធានការការពារត្រូវបានអនុញ្ញាតិសមស្របតាមលក្ខខណ្ឌជាក់លាក់។

### D314 វិធានការការពារដែលមានទម្រង់ផ្សេងទៀត

ជាវិធានការការពារដែលមានទម្រង់ផ្សេងទៀតក្រៅពីកាតព្វកិច្ចពន្ធគយ ឬការរឹតត្បិតជាបរិមាណ (ដែលអាចជាវិធានការរួមបញ្ចូលគ្នាទាំងកាតព្វកិច្ចពន្ធគយនិងបរិមាណ) ត្រូវបានអនុវត្តដើម្បីការពារ ឬប៉ះប៉ូវការរងខូចខាតធ្ងន់ធ្ងរពីការកើនឡើងនៃការនាំចូល (ដូចដែលត្រូវបានបង្កើតឡើងនៅក្នុងការស៊ើបអង្កេត) និងដើម្បីជួយសម្របសម្រួលដល់ការកែតម្រូវ។ ប្រសិនបើរយៈពេលរំពឹងទុកនៃវិធានការគឺច្រើនជាងមួយឆ្នាំ សេរីភាវូបនីយកម្មត្រូវធ្វើជាបណ្ដើរៗ ក្នុងអំឡុងពេលរយៈពេលនៃការអនុវត្តវិធានការ។

***ឧទាហរណ៍÷*** *វិធានការការពាររយៈពេល ២ឆ្នាំ ត្រូវបានអនុវត្តលើការនាំចូលម៉ាស៊ីនលាងចាន។ ក្នុងកំឡុងឆ្នាំទីមួយ ទឹកប្រាក់ពន្ធ ៥០ ដុល្លារ ក្នុងមួយឯកតានឹងត្រូវបានអនុវត្តលើម៉ាស៊ីនលាង*

*ចានដែលនាំចូលទាំងអស់ ដែលមានភ្ជាប់តម្លៃ c.i.f. ក្រោម ៥០០ ដុល្លារក្នុងមួយឯកតា។ ក្នុងឆ្នាំទីពីរ វិធានការការពារនឹងមិនត្រូវអនុវត្តចំពោះការនាំចូល ២០.០០០ គ្រឿងដំបូងឡើយ ដោយមិនគិតពីតម្លៃនៃគ្រឿងទាំងនោះ។*

**D32 វិធានការការពារវិស័យកសិកម្មពិសេស**

ជាវិធានការការពារវិស័យកសិកម្មពិសេសអនុញ្ញាតដែលឱ្យមានការដាក់ពន្ធបន្ថែម ដើម្បីឆ្លើយតបនឹងការកើនឡើងនៃការនាំចូល ឬការធ្លាក់ចុះនៃការនាំចូលតម្លៃ។ កម្រិតជាក់លាក់សម្រាប់បរិមាណឬតម្លៃនៃទំនិញនាំចូល គឺជាការកំណត់នៅក្នុងកម្រិតប្រទេស។ ក្នុងករណីដែលបញ្ហាបង្កឡើងដោយបរិមាណនាំចូល កាតព្វកិច្ចបន្ថែមត្រូវអនុវត្តរហូតដល់ដំណាច់ឆ្នាំ។ ក្នុងករណីតម្លៃដែលបង្កការខូចខាត (Price Triggers) កាតព្វកិច្ចបន្ថែមត្រូវបានកំណត់លើការដឹកជញ្ជូនតាមមូលដ្ឋាននៃការដឹកជញ្ជូន។

**D321 វិធានការការពារសុវត្ថិភាពផលិតផលកសិកម្មផ្អែកលើទំហំពាណិជ្ជកម្ម**

នៅក្នុងវិធានការការពារប្រភេទនេះ កាតព្វកិច្ចបន្ថែមអាចត្រូវបានអនុវត្ត ប្រសិនបើទំហំនៃការនាំចូលផលិតផលកសិកម្មលើសបរិមាណដែលបានកំណត់។

***ឧទាហរណ៍÷*** *កាតព្វកិច្ចពន្ធបន្ថែមស្មើនឹងមួយភាគបីនៃកាតព្វកិច្ចពន្ធបច្ចុប្បន្ន ត្រូវបានអនុវត្តចំពោះការនាំចូលទឹកដោះគោ នៅពេលបរិមាណការនាំចូលលើសបរិមាណកំណត់ ៨៧១ តោន។*

**D322 វិធានការការពារផលិតផលកសិកម្មពិសេសផ្អែកលើតម្លៃពាណិជ្ជកម្ម**

នៅក្នុងវិធានការការពារប្រភេទនេះ កាតព្វកិច្ចពន្ធបន្ថែមអាចត្រូវបានអនុវត្ត ប្រសិនបើតម្លៃនាំចូលនៃផលិតផលកសិកម្មដែលបានកំណត់ធ្លាក់ចុះខាងក្រោមតម្លៃដែលបានកំណត់។

***ឧទាហរណ៍÷*** *កាតព្វកិច្ចពន្ធបន្ថែម ២,៧៩ Php/គីឡូក្រាម ត្រូវបានអនុវត្តលើការដឹកជញ្ជូនសាច់កកនិងសត្វបក្សី Gallus domesticus នៅពេលដែល តម្លៃនាំចូល c.i.f. របស់ការដឹកជញ្ជូននោះទាបជាងតម្លៃកំណត់ ៩៣ Php/ គីឡូក្រាម ២០ ភាគរយ។*

**D39 វិធានការការពារផ្សេងទៀត ក្រៅពីវិធានការខាងលើ**

វិធានការប្រភេទនេះអាចរួមមានដូចជា÷ យន្តការនៃវិធានការការពារពិសេសដែលអាចអនុវត្តចំពោះការនាំចូលផលិតផលក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងតំបន់ ពិធីការនៃការចូល ឬកិច្ចព្រមព្រៀងផ្សេងទៀត។

---

[3] វិធានការគ្រប់គ្រងបរិមាណភាគច្រើនត្រូវបានហាមឃាត់ជាផ្លូវការដោយកិច្ចព្រមព្រៀងទូទៅស្តីពីតារាងពន្ធ និងពាណិជ្ជកម្ម (GATT) ១៩៩៤ ប៉ុន្តែអាចអនុវត្តបាននៅក្រោមកាលៈទេសៈដែលបានកំណត់ជាក់លាក់ (ឧទាហរណ៍÷ មាត្រា XI នៃ GATT ១៩៩៤ កិច្ចព្រមព្រៀងស្តីពីការការពារ។)

## E ការផ្តល់អាជ្ញាប័ណ្ណមិនមែនស្វ័យប្រវត្តិកម្ម, កូតា, ការហាមឃាត់ និងវិធានការគ្រប់គ្រងបរិមាណផ្សេងទៀត ក្រៅពីសម្រាប់ហេតុផល អនាម័យ និងភូតគាមអនាម័យ (SPS) ឬ របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (TBT)

វិធានការគ្រប់គ្រងជាទូទៅមានគោលបំណងរឹតត្បិតបរិមាណទំនិញដែលអាចត្រូវបាននាំចូលដោយមិនគិតថា តើទំនិញទាំងនោះមកពីប្រភពផ្សេងៗគ្នា ឬអ្នកផ្គត់ផ្គង់ជាក់លាក់មួយឡើយ។ វិធានការទាំងនេះអាចជាការផ្តល់អាជ្ញាប័ណ្ណមិនមែនស្វ័យប្រវត្តិកម្ម ការកែតម្រូវកូតាដែលបានកំណត់ជាមុន ឬតាមរយៈការហាមឃាត់ៗ វិធានការទាំងអស់ត្រូវបានដាក់ណែនាំសម្រាប់ហេតុផល SPS និង TBT ដែលត្រូវបានចាត់ថ្នាក់ក្នុងជំពូក A និង B ខាងលើ។

### E1 និតិវិធីក្នុងការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការនាំចូលមិនមែនស្វ័យប្រវត្តិកម្មក្រៅពីហេតុផលSPS ឬTBT

នីតិវិធីផ្តល់អាជ្ញាបណ្ណក្នុងការនាំចូលត្រូវបានណែនាំសម្រាប់ហេតុផលក្រៅពី SPS ឬ TBT ដែលការអនុញ្ញាតមិនត្រូវបានផ្តល់ឱ្យក្នុងករណីទាំងអស់។ ការអនុញ្ញាតអាចត្រូវបានផ្តល់ជូនតាមការវិនិច្ឆ័យជាមូលដ្ឋាន ឬក៏អាចតម្រូវឱ្យមានលក្ខខណ្ឌជាក់លាក់ជាមុន។

#### E11 ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ហេតុផលសេដ្ឋកិច្ច

##### E111 នីតិវិធីផ្តល់អាជ្ញាប័ណ្ណដោយគ្មានលក្ខណៈបុរេវិនិច្ឆ័យជាក់លាក់

នីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណដែលការផ្តល់ឱ្យស្ថិតនៅលើសេចក្តីសម្រេចរបស់អាជ្ញាធរ ក៏អាចសំដៅលើអាជ្ញាប័ណ្ណដែលចាំបាច់ផងដែរ។

***ឧទាហរណ៍÷*** *ការនាំចូលផលិតផលវាយនភ័ណ្ឌគឺត្រូវបានអនុញ្ញាតដោយផ្អែកលើអាជ្ញាប័ណ្ណដែលសម្រេចដោយអាជ្ញាធរពាក់ព័ន្ធ។*

##### E112 អាជ្ញាប័ណ្ណសម្រាប់ការប្រើប្រាស់ជាក់លាក់

ជានិតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ ដែលត្រូវបានផ្តល់ជូនសម្រាប់តែការនាំចូលផលិតផលដែលត្រូវប្រើសម្រាប់ការបញ្ជាក់គោលបំណងជាមុនៈ ជាធម្មតាត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់ក្នុងប្រតិបត្តិការបង្កើតផលប្រយោជន៍ដែលបានរំពឹងទុកនៅក្នុងដែនសំខាន់ៗនៃសេដ្ឋកិច្ច។

***ឧទាហរណ៍÷*** *អាជ្ញាប័ណ្ណក្នុងការនាំចូលគ្រឿងផ្ទុះដែលមានថាមពលខ្ពស់នឹងត្រូវផ្តល់ជូនតែក្នុងករណីដែលវាត្រូវត្រូវប្រើប្រាស់សម្រាប់ឧស្សាហកម្មរ៉ែតែប៉ុណ្ណោះ។*

##### E113 អាជ្ញាប័ណ្ណទាក់ទងនឹងផលិតកម្មក្នុងស្រុក

ការផ្តល់អាជ្ញាប័ណ្ណសម្រាប់តែការនាំចូលផលិតផលដែលទាក់ទងទៅនឹងផលិតផលក្នុងស្រុក រួមទាំងកម្រិតផលិតកម្មក្នុងស្រុកដែលដូចគ្នា លើកលែងតែការផ្តល់អាជ្ញាប័ណ្ណដែលត្រូវបានចាត់ថ្នាក់ ថាជាវិធានការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មដូចដែលបានកំណត់ក្នុងជំពូក ១។

***ឧទាហរណ៍÷*** *អាជ្ញាប័ណ្ណក្នុងការនាំចូលប្រេងសាំងត្រូវបានផ្តល់ជូនប្រសិនបើការផ្គត់ផ្គង់ក្នុងស្រុកមិនគ្រប់គ្រាន់ទេ។*

**E119 ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ហេតុផលសេដ្ឋកិច្ចផ្សេងទៀត ក្រៅពីវិធានការខាងលើ**

**E12 ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ហេតុផលមិនមែនសេដ្ឋកិច្ច**

**E121 អាជ្ញាប័ណ្ណសម្រាប់ហេតុផលសាសនា សីលធម៌ ឬវប្បធម៌**

ការគ្រប់គ្រងការនាំចូលតាមរយៈអាជ្ញាប័ណ្ណសម្រាប់ហេតុផលសាសនា សីលធម៌ ឬវប្បធម៌។

***ឧទាហរណ៍៖*** *ការនាំចូលភេសជ្ជៈដែលមានជាតិអាល់កុលត្រូវបានអនុញ្ញាតឱ្យនាំចូលសម្រាប់តែសណ្ឋាគារនិងភោជនីយដ្ឋានតែប៉ុណ្ណោះ។*

**E122 ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ហេតុផលនយោបាយ**

ការគ្រប់គ្រងការនាំចូលដោយអាជ្ញាប័ណ្ណសម្រាប់ហេតុផលនយោបាយ។

***ឧទាហរណ៍៖*** *ការនាំចូលផលិតផលទាំងអស់ពីប្រទេសកំណត់គឺត្រូវមានអាជ្ញាប័ណ្ណនាំចូល។*

**E129 អាជ្ញាប័ណ្ណ សម្រាប់ហេតុផលមិនមែនសេដ្ឋកិច្ច ក្រៅពីវិធានការខាងលើ**

## E2 កូតា

ការដាក់កំហិតលើការនាំចូលផលិតផល ដែលបានបញ្ជាក់តាមរយៈការកំណត់បរិមាណឬតម្លៃអតិបរមាដែលត្រូវបានអនុញ្ញាតសម្រាប់ការនាំចូល៖ មិនអនុញ្ញាតឱ្យមានការនាំចូលដែលលើសពីចំនួនអតិបរមាកំណត់ទាំងនោះទេ។

**E21 អចិន្ត្រៃយ៍**

កូតានៃធម្មជាតិអចិន្ត្រៃយ៍ (*ឧទាហរណ៍៖* កូតាទាំងនេះត្រូវបានអនុវត្តពេញមួយឆ្នាំដោយគ្មានកំណត់កាលបរិច្ឆេទនៃការបញ្ចប់វិធានការឡើយ) ដែលការនាំចូលអាចកើតឡើងនៅពេលណាក៏បាន។

**E211 ការបែងចែកជាសកល**

ជាកូតាអចិន្ត្រៃយ៍ដែលគ្មានការកំណត់លក្ខខណ្ឌសម្រាប់ប្រទេសនៃផលិតផលដើមកំណើត។

***ឧទាហរណ៍៖*** *កូតាលើត្រីចំនួន ១០០ តោន ដែលអាចនាំចូលគ្រប់ពេលនៅក្នុងឆ្នាំ ហើយមិនមានការរឹតត្បិតលើប្រទេសនៃផលិតផលដើមកំណើតឡើយ។*

**E212 ការបែងចែកប្រទេស**

ជាកូតាអចិន្ត្រៃយ៍ដែលទំហំពាណិជ្ជកម្មឬតម្លៃថេររបស់ផលិតផល ត្រូវតែមានប្រភពដើមកំណើតនៅក្នុងប្រទេសមួយឬច្រើន។

***ឧទាហរណ៍៖*** *កូតាត្រីចំនួន ១០០ តោន ដែលអាចនាំចូលបានគ្រប់ពេលនៅក្នុងឆ្នាំ ប៉ុន្តែ ៧៥ តោន ត្រូវតែមានដើមកំណើតមកពីប្រទេសA និង ២៥ តោនមកពីប្រទេសB។*

**E22 កូតាតាមរដូវ**

ជាកូតាធម្មជាតិអចិន្ត្រៃយ៍ (ឧទាហរណ៍៖ កូតាទាំងនេះត្រូវបានអនុវត្តជារៀងរាល់ឆ្នាំដោយគ្មានកាលបរិច្ឆេទនៃការបញ្ចប់វិធានការឡើយ) ដែលការនាំចូលត្រូវតែធ្វើឡើងក្នុងកំឡុងពេលកំណត់មួយ។

**E221 ការបែងចែកសកល**

ជាកូតាតាមរដូវកាលដែលគ្មានការកំណត់លក្ខខណ្ឌសម្រាប់ប្រទេសនៃផលិតផលដើមកំណើត។

***ឧទាហរណ៍÷*** *កូតាប្រចាំឆ្នាំលើសារ៉ាយសមុទ្រចំនួន ៣០០ តោន ដែលការនាំចូលត្រូវធ្វើឡើងនៅចន្លោះ ខែមីនានិងខែមិថុនា ហើយមិនមានការរឹតត្បិតលើប្រទេសនៃផលិតផលដើមកំណើតទេ។*

**E222 ការបែងចែកប្រទេស**

ជាកូតាតាមរដូវកាលដែលទំហំពាណិជ្ជកម្មឬតម្លៃថេររបស់ផលិតផល ត្រូវតែមានប្រភពដើមកំណើតនៅក្នុងប្រទេសមួយឬច្រើន។

***ឧទាហរណ៍÷*** *កូតាប្រចាំឆ្នាំលើសារ៉ាយសមុទ្រចំនួន ៣០០ តោន ដែលអាចនាំចូលបានតែនៅក្នុងរដូវរងារ ហើយ ៦០ តោន ត្រូវតែមានដើមកំណើតមកពីប្រទេសA និង ៤០ តោន មកពីប្រទេសB។*

**E23 បណ្ដោះអាសន្ន**

ជាកូតាដែលត្រូវបានអនុវត្តលើមូលដ្ឋានបណ្ដោះអាសន្ន (ឧទាហរណ៍÷ កូតាទាំងនេះត្រូវបានអនុវត្តមួយឬពីរឆ្នាំតែប៉ុណ្ណោះ) ទោះបីជាកូតារដូវឬមិនមែនក៏ដោយ។

**E231 ការបែងចែកសកល**

ជាកូតាតាបណ្ដោះអាសន្នដែលគ្មានការកំណត់លក្ខខណ្ឌសម្រាប់ប្រទេសនៃផលិតផលដើមកំណើត។

ឧទាហរណ៍÷ កូតាប្រចាំឆ្នាំលើត្រីនិងសាច់ត្រីចំនួន ១.០០០ តោន ដែលនឹងត្រូវបានអនុវត្តក្នុងរយៈពេលតែបីឆ្នាំដោយមិនមានការរឹតត្បិតលើប្រទេស នៃផលិតផលដើមកំណើតឡើយ។

**E232 ការបែងចែកប្រទេស**

ជាកូតាតាបណ្ដោះអាសន្ន ដែលទំហំពាណិជ្ជកម្មឬតម្លៃថេររបស់ផលិតផល ត្រូវតែមានប្រភពដើមកំណើតនៅក្នុងប្រទេសមួយឬច្រើន។

***ឧទាហរណ៍÷*** *កូតាប្រចាំឆ្នាំលើត្រីនិងសាច់ត្រីចំនួន ១.០០០ តោន ដែលនឹងត្រូវបានអនុវត្តក្នុងរយៈពេលតែបីឆ្នាំប៉ុណ្ណោះ ដែលការនាំចូលត្រូវតែធ្វើឡើងក្នុងរដូវក្ដៅ ហើយ ៧០០ តោន ត្រូវតែមានដើមកំណើតនៅក្នុងប្រទេស A និង 200 តោនទៀត ត្រូវតែមានដើមកំណើតនៅក្នុងប្រទេស B និងនៅសល់អាចមានដើមកំណើតនៅក្នុងប្រទេសណាមួយទៀតក៏បាន។*

E3 ការហាមឃាត់ក្រៅពីហេតុផល SPS និង TBT

ជាការហាមឃាត់លើការនាំចូលផលិតផលជាក់លាក់សម្រាប់ហេតុផលផ្សេងទៀតក្រៅពីហេតុផល SPS (A1) ឬ TBT (B1)។

**E31 ការហាមឃាត់សម្រាប់ហេតុផលសេដ្ឋកិច្ច**

**E311 ការហាមឃាត់ពេញលេញ (ការហាមឃាត់ការនាំចូល)**

ជាការហាមឃាត់ដោយគ្មានលក្ខខណ្ឌឬគុណវុឌ្ឍិបន្ថែម។

***ឧទាហរណ៍÷*** ការនាំចូលយានយន្តដែលមានស៊ីឡាំងក្រោម ១.៥០០ cc មិនត្រូវបានអនុញ្ញាតទេ ដើម្បីលើកទឹកចិត្តនិងគាំទ្រដល់ផលិតកម្មក្នុងស្រុក។

**E312 ការហាមឃាត់តាមរដូវ**

ជាការហាមឃាត់ការនាំចូលក្នុងកំឡុងពេលណាមួយដែលបានកំណត់ក្នុងឆ្នាំ÷ វិធានការនេះជាធម្មតាត្រូវបានអនុវត្តទៅលើផលិតផលកសិកម្មជាក់លាក់មួយចំនួន នៅកំឡុងពេលនៃការប្រមូលផលក្នុងស្រុក។

***ឧទាហរណ៍÷*** ការនាំចូលផ្លែស្ត្របឺរីមិនត្រូវបានអនុញ្ញាតិពីខែមីនាដល់ខែមិថុនារៀងរាល់ឆ្នាំ។

**E313 ការហាមឃាត់ជាបណ្តោះអាសន្នរួមទាំងការព្យួរការផ្តល់អាជ្ញាប័ណ្ណ**

ជាកម្រងនៃការហាមឃាត់ក្នុងរយៈពេលជាក់លាក់ណាមួយ ដែលមិនទាក់ទងនឹងរដូវកាលជាក់លាក់ណាមួយ÷ ជាធម្មតាសម្រាប់បញ្ហាបន្ទាន់ដែលមិនត្រូវបានអនុវត្តក្រោមវិធានការពារខាងលើ។

***ឧទាហរណ៍÷*** ការនាំចូលត្រីមួយចំនួនត្រូវហាមឃាត់ភ្លាមៗ រហូតដល់ចុងបញ្ចប់នៃរដូវកាលបច្ចុប្បន្ន។

**E314 ការហាមឃាត់ការនាំចូលក្នុងបរិមាណច្រើន**

ការហាមឃាត់ការនាំចូលជាកុងតឺន័រ ដែលមានបរិមាណច្រើនៈ ការនាំចូលត្រូវបានអនុញ្ញាតលុះត្រាតែផលិតផលត្រូវបានដាក់បញ្ចូលកុងតឺន័រសម្រាប់ការលក់រាយដែលបង្កើនថ្លៃការនាំចូលក្នុងមួយឯកតា។

***ឧទាហរណ៍÷*** ការនាំចូលស្រាត្រូវបានអនុញ្ញាតិតែដបដែលមានចំណុះ ៧៥0ml ឬតិចជាងនេះប៉ុណ្ណោះ។

**E315 ការហាមឃាត់ផលិតផលដែលរំលោភលើប៉ាតង់ឬកម្មសិទ្ធិបញ្ញាផ្សេងទៀត**

ការហាមឃាត់ការចម្លងឬការធ្វើត្រាប់តាមកម្មសិទ្ធិបញ្ញា ឬផលិតផលយីហោ។

***ឧទាហរណ៍÷*** ការនាំចូលកាបូបដៃម៉ាកក្លែងក្លាយត្រូវបានហាមឃាត់។

**E316 ការហាមឃាត់ចំពោះទំនិញដែលត្រូវបានប្រើប្រាស់ ជួសជុល ឬកែច្នៃឡើងវិញ**

ការហាមឃាត់ការនាំចូលទំនិញដែលមិនមែនជាផលិតផលថ្មី។

***ឧទាហរណ៍÷*** ការហាមឃាត់មិនឱ្យនាំចូលរថយន្តជជុះ។

**E319 ការហាមឃាត់ដោយសារហេតុផលសេដ្ឋកិច្ចផ្សេងទៀត ក្រៅពីវិធានការខាងលើ**

**E321 ការហាមឃាត់ដោយសារហេតុផលមិនមែនសេដ្ឋកិច្ច**

**E321 ការហាមឃាត់ដោយសារហេតុផលសាសនា សីលធម៌ ឬវប្បធម៌**

ការហាមឃាត់ការនាំចូលដោយសារហេតុផលសាសនា សីលធម៌ ឬវប្បធម៌មិនត្រូវបានបង្កើតឡើងនៅក្នុងបទបញ្ញាបច្ចេកទេស។

***ឧទាហរណ៍÷*** *ការនាំចូលសៀវភៅនិងទស្សនាវដ្ដីបរភាពអាសអាភាសត្រូវហាមឃាត់។*

**E322 ការហាមឃាត់ដោយសារហេតុផលនយោបាយ (ទណ្ឌកម្មពាណិជ្ជកម្ម)**

ការហាមឃាត់ការនាំចូលពីប្រទេសមួយឬក្រុមប្រទេសមួយត្រូវបានអនុវត្តដោយសារហេតុផលនយោបាយ។

***ឧទាហរណ៍÷*** *ការនាំចូលទំនិញទាំងអស់ពីប្រទេស A គឺត្រូវបានហាមឃាត់ក្នុងការដាក់ទណ្ឌកម្មចំពោះការសាកល្បងគ្រាប់បែកនុយក្លេអ៊ែររបស់ប្រទេសនោះ ។*

**E329 ការហាមឃាត់ដោយសារហេតុផលមិនមែនសេដ្ឋកិច្ចផ្សេងទៀត ក្រៅពីវិធានការខាងលើ**

E5 ការរឹតត្បិតលើការនាំចេញ

ជាកិច្ចព្រមព្រៀងដែលអ្នកនាំចេញយល់ព្រមក្នុងការកំណត់ការនាំចេញដើម្បីចៀសវាងការរឹតត្បិតដោយប្រទេសដែលនាំចូល ដូចជាកូតា ការតំឡើងពន្ធគយ ឬវិធានការសម្រាប់ការគ្រប់គ្រងការនាំចូលផ្សេងទៀត[4] កិច្ចយល់ព្រមនេះអាចបញ្ចប់នៅទាំងកម្រិតរដ្ឋាភិបាល ឬកម្រិតឧស្សាហកម្ម។

**E51 ការរឹតត្បិតលើការនាំចេញដោយស្ម័គ្រចិត្ត (VERs)**

ជាកិច្ចព្រមព្រៀងរៀបចំដោយរដ្ឋាភិបាល ឬឧស្សាហកម្មនៃប្រទេសនាំចេញ ដើម្បីកំណត់ការនាំចេញដោយស្ម័គ្រចិត្ត ដើម្បីចៀសវាងការរឹតត្បិតជាកាតព្វកិច្ចដោយប្រទេសនាំចូល។ ជាធម្មតា VERs គឺជាលទ្ធផលនៃសំណើដែលធ្វើឡើងដោយប្រទេសនាំចូលដើម្បីផ្ដល់ជាវិធានការការពារធុរៈកិច្ចក្នុងស្រុកដែលផលិតទំនិញជំនួស។

**E511 កិច្ចព្រមព្រៀងជាកូតា**

ជាកិច្ចព្រមព្រៀង VER ដែលបង្កើតកូតានាំចេញ។

***ឧទាហរណ៍÷*** កូតាទ្វេភាគីលើការនាំចេញទោចក្រយានយន្តពីប្រទេស A ទៅប្រទេស B ត្រូវបានបង្កើតឡើងដើម្បីចៀសវាងការដាក់ទណ្ឌកម្មដោយប្រទេស B។

**E512 កិច្ចព្រមព្រៀងពិគ្រោះយោបល់**

ជាកិច្ចព្រមព្រៀង VER ដែលផ្ដល់ការប្រឹក្សាយោបល់ និងការណែនាំអំពីការដាក់កំរិត (កូតា) ក្នុងកាលៈទេសៈជាក់លាក់។

---

[4] កិច្ចព្រមព្រៀងបែបនេះត្រូវបានហាមឃាត់ជាផ្លូវការដោយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

***ឧទាហរណ៍÷*** ការយល់ព្រមក្នុងដាក់កំហិតការនាំចេញកប្បាសពីប្រទេស C ទៅប្រទេស D ក្នុងករណីទំហំនៃការនាំចេញលើសពី ២ លានដុល្លារ កាលពីខែមុន។

**E513 កិច្ចព្រមព្រៀងសហប្រតិបត្តិការរដ្ឋបាល**

ជាកិច្ចព្រមព្រៀង VER ដែលផ្តល់ជូនកិច្ចសហប្រតិបត្តិការរដ្ឋបាល ដោយយល់ថាដើម្បីចៀសវាងការរំខាននៅក្នុងពាណិជ្ជកម្មទ្វេភាគី។

***ឧទាហរណ៍÷*** *ការយល់ព្រមបង្កើតកិច្ចព្រមព្រៀងរវាងប្រទេស E និងប្រទេស F ដើម្បីសហការដើម្បីទប់ស្កាត់ការកើនឡើងភ្លាមៗនៃការនាំចេញ។*

**E59 កិច្ចយល់ព្រមក្នុងការរឹតត្បិតការនាំចេញផ្សេងទៀត ក្រៅពីវិធានការខាងលើ**

E6 អត្រាពន្ធគិតជាកូតា (TRQ)

ជាប្រព័ន្ធនៃអត្រាពន្ធច្រើន ដែលអនុវត្តចំពោះផលិតផលតែមួយៈ អត្រាពន្ធដែលទាបជាងត្រូវបានអនុវត្តលើតម្លៃឬទំហំពាណិជ្ជកម្មជាក់លាក់មួយនៃការនាំចូល និងអត្រាពន្ធខ្ពស់ជាងត្រូវបានអនុវត្តលើការនាំចូលដែលមានតម្លៃឬទំហំពាណិជ្ជកម្មលើសពីនេះ។

***ឧទាហរណ៍÷*** អង្ករអាចត្រូវបាននាំចូលដោយមិនគិតពន្ធរហូតដល់ ១០០,០០០ តោនដំបូង សម្រាប់អង្ករដែលនាំចូលមានចំនួនលើសពីនោះ នឹងត្រូវបង់ពន្ធ ១.៥ ដុល្លារ ក្នុងមួយគីឡូក្រាម។

**E61 អត្រាពន្ធគិតជាកូតា ដែលចងភ្ជាប់ដោយអង្គការពាណិជ្ជកម្មពិភពលោក រួមបញ្ចូលនៅក្នុងតារាងពន្ធគយរបស់អង្គការពាណិជ្ជកម្មពិភពលោក (សម្បទាននិងការប្តេជ្ញាចិត្តក្រោមការចរចាររបស់អង្គការពាណិជ្ជកម្មពិភពលោក)**

**E611 ការបែងចែកជាសកល**

ជា WTO-bound TRQs ដែលគ្មានលក្ខខណ្ឌត្រូវបានកំណត់លើប្រទេសផលិតផលដើមកំណើត។

***ឧទាហរណ៍÷*** *WTO-bound TRQ អនុញ្ញាតឱ្យនាំចូលទឹកដោះគោ និងក្រែមរហូតដល់ ២.០០០ តោន ដោយមិនបង់ពន្ធ និងមិនមានលក្ខខណ្ឌកំណត់លើប្រទេសនៃផលិតផលដើមកំណើត។*

**E612 ការបែងចែកតាមប្រទេស**

ជា WTO-bound TRQs ដែលទំហំពាណិជ្ជកម្មឬតម្លៃផលិតផលថេរ ត្រូវតែមានដើមកំណើតនៅក្នុងប្រទេសមួយឬច្រើន។

***ឧទាហរណ៍÷*** *ការអនុវត្ត WTO TRQs លើបសុបក្សីចំនួន ២០០,០០០ តោន ដោយគិតជាកូតា ១២% និងពាក់កណ្តាលនៃចំនួននោះ ត្រូវមានដើមកំណើតពីប្រទេស A។*

**E62 TRQ ដែលរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មផ្សេងទៀត**

**E621 ការបែងចែកជាសកល**

ជា TRQ ដែលមិនមានចែងដោយអង្គការពាណិជ្ជកម្មពិភពលោក (non-WTO TRQ) ដែលគ្មានលក្ខខណ្ឌកំណត់លើប្រទេសនៃផលិតផលដើមកំណើត។

***ឧទាហរណ៍÷*** *non-WTO TRQ អាចប្រើប្រាស់បានសម្រាប់តែសាច់គោចំនួន ៤០.០០០ តោន ដោយគ្មានការកំណត់លក្ខខណ្ឌសម្រាប់ប្រទេសនៃផលិតផលដើមកំណើតឡើយ។*

**E622 ការបែងចែកប្រទេស**

ជា TRQ ដែលមិនមានចែងដោយអង្គការពាណិជ្ជកម្មពិភពលោក (non-WTO TRQ) ដែលបរិមាណឬតម្លៃនៃផលិតផលថេរ ត្រូវតែមានដើមកំណើតនៅក្នុងប្រទេសមួយឬច្រើន។

***ឧទាហរណ៍÷*** *ចេកស្រស់ពីប្រទេស A អាចត្រូវបាននាំចូលដោយមិនគិតពន្ធរហូតដល់ ៤.០០០ តោន។*

E9 វិធានការត្រួតពិនិត្យបរិមាណផ្សេងទៀត ក្រៅពីវិធានការខាងលើ

F **វិធានការគ្រប់គ្រងតម្លៃ ដែលបូកបញ្ចូលពន្ធនិងតម្លៃបន្ថែម**

ជាវិធានការដែលបានអនុវត្តដើម្បីគ្រប់គ្រងឬមានឥទ្ធិពលលើតម្លៃទំនិញនាំចូល ដើម្បីគាំទ្រតម្លៃនៃផលិតផលក្នុងស្រុកមួយចំនួននៅពេលដែលតម្លៃទំនិញនាំចូលទាំងនោះទាបជាង; បង្កើតតម្លៃជាក់លាក់សម្រាប់ផលិតផលក្នុងស្រុក ដោយសារតែការប្រែប្រួលតម្លៃនៅក្នុងទីផ្សារក្នុងស្រុក ឬអស្ថិរភាពតម្លៃនៅក្នុងទីផ្សារបរទេស; ឬដើម្បីបង្កើន ឬការពារប្រាក់ចំណូលដែលបានមកពីការប្រមូលពន្ធ។ វិធានការប្រភេទនេះក៏រាប់បញ្ចូលទាំងវិធានការក្រៅពីពន្ធដែលបង្កើនថ្លៃដើមនៃការនាំចូលក្នុងលក្ខណៈប្រហាក់ប្រហែលគ្នា ពោលគឺតាមរយៈការគិតជាភាគរយថេរឬចំនួនថេរ។ ពួកគេក៏ត្រូវបានស្គាល់ថាជាវិធានការពន្ធគយ។

F1 វិធានការរដ្ឋបាលដែលប៉ះពាល់ដល់តម្លៃពន្ធគយ

ជាការកំណត់តម្លៃនាំចូលដោយអាជ្ញាធរនៃប្រទេសនាំចូល ដោយគិតគូរពីតម្លៃផលិតផលក្នុងស្រុកសម្រាប់អ្នកផលិត ឬអ្នកប្រើប្រាស់។ វិធាននេះអាចមានទម្រង់ជាការបង្កើតកម្រិតតម្លៃអប្បបរមានិងតម្លៃអតិបរមា ឬប្តូរទៅជាការកំណត់តម្លៃតាមទីផ្សារអន្តរជាតិ។ វាអាចមានភាពខុសគ្នាក្នុងការកំណត់តម្លៃនាំចូល ដូចជាតម្លៃនាំចូលអប្ប- បរមា ឬតម្លៃដែលត្រូវបានកំណត់ដោយផ្អែកលើករណីយោង។

**F11 តម្លៃនាំចូលអប្បបរមា**

ជាតម្លៃនាំចូលដែលត្រូវបានបង្កើតជាមុន ដែលកំណត់ថាការនាំចូលណាមួយដែលមិនអាចអនុញ្ញាតិ។

***ឧទាហរណ៍÷*** តម្លៃនាំចូលអប្បបរមាត្រូវបានបង្កើតឡើងសម្រាប់ផលិតផលក្រណាត់និងសម្លៀកបំពាក់។

**F12 តម្លៃយោង**

ជាថ្លៃដើមដែលត្រូវបានបង្កើតឡើងជាមុន ដែលអាជ្ញាធរនៃប្រទេសនាំចូលប្រើជាឯកសារយោងដើម្បីផ្ទៀងផ្ទាត់តម្លៃទំនិញនាំចូល។

***ឧទាហរណ៍៖*** តម្លៃយោងសម្រាប់ផលិតផលកសិកម្ម គឺផ្អែកលើតម្លៃកសិដ្ឋាន ដែលជាតម្លៃសុទ្ធរបស់ផលិតផលនៅពេលវាទុកកសិដ្ឋានបន្ទាប់ពីថ្លៃទីផ្សារត្រូវបានដក។

**F19 វិធានការរដ្ឋបាលដទៃទៀតដែលប៉ះពាល់ដល់តម្លៃពន្ធគយផ្សេងទៀត ក្រៅពីវិធានការខាងលើ**

F2 ការរឹតត្បិតតម្លៃនាំចេញដោយស្ម័គ្រចិត្ត (VEPRs)

ជាកិច្ចព្រមព្រៀងដែលអ្នកនាំចេញយល់ព្រមរក្សាតម្លៃទំនិញលើសកម្រិតជាក់លាក់៖[5] ដំណើរការនៃវិធានការ VEPR ត្រូវបានផ្តួចផ្តើមឡើង ដោយប្រទេសនាំចូល ដូច្នេះត្រូវបានគេចាត់ទុកថាជាវិធានការលើការនាំចូល។

***ឧទាហរណ៍៖*** តម្លៃនាំចេញនៃកាសែតវីដេអូត្រូវបានកំណត់ខ្ពស់ជាងមុន ដើម្បីកាត់បន្ថយភាពមិនចុះសម្រុងក្នុងការធ្វើពាណិជ្ជកម្មជាមួយប្រទេសនាំចូលធំៗ។

F3 ថ្លៃសេវាអថេរ

ពន្ធ ឬប្រាក់ទូទាត់ជូនរដ្ឋាភិបាល ដែលត្រូវបានប្រមូលក្នុងគោលបំណងធ្វើឱ្យតម្លៃទីផ្សារនៃផលិតផលនាំចូលមានកម្រិតប្រហាក់ប្រហែលទៅនឹងតម្លៃទីផ្សារនៃផលិតផលក្នុងស្រុក៖[6] ទំនិញដែលត្រូវបានប្រើប្រាស់ជាវត្ថុធាតុដើមអាចនឹងត្រូវបានគិតពន្ធផ្អែកទៅលើទម្ងន់សរុប ខណៈដែលម្ហូបអាហារកែច្នៃអាចនឹងត្រូវគិតពន្ធផ្អែកលើសមាមាត្រនៃសមាសធាតុវត្ថុធាតុដើមក្នុងផលិតផលសម្រេច។ ការគិតពន្ធទាំងនេះរួមមាន៖

**F31 ពន្ធអថេរ**

អត្រាពន្ធ ឬប្រាក់ទូទាត់ជូនរដ្ឋាភិបាលផ្លាស់ប្តូរផ្ទុយពីតម្លៃនៃផលិតផលនាំចូល ដើម្បីរក្សាស្ថិរភាពនៃតម្លៃទំនិញក្នុងប្រទេសនាំចូល៖ អនុវត្តជាចម្បងចំពោះវត្ថុធាតុដើមនិងអាចហៅបានថាកម្រៃនាំចូលអថេរ (flexible import fee)។

***ឧទាហរណ៍៖** តម្លៃគោលដៅសម្រាប់គ្រាប់ពូជគឺ ៧០០ដុល្លារក្នុងមួយតោន។ ដោយសារតម្លៃគ្រាប់ពូជលើទីផ្សារអន្តរជាតិស្មើនឹង ៥០០ដុល្លារ នោះពន្ធនឹងស្មើ ២០០ដុល្លារ។ ប្រសិនបើតម្លៃគ្រាប់ពូជលើទីផ្សារអន្តរជាតិប្តូរទៅ ៦០០ដុល្លារ នោះពន្ធនឹងប្តូរទៅ ១០០ដុល្លារ។*

**F32 សមាសភាគអថេរ**

អត្រាពន្ធ ឬប្រាក់ទូទាត់ជូនរដ្ឋាភិបាលរាប់បញ្ចូលសមាសភាគ ad valorem និងសមាសភាគអថេរ៖ ថ្លៃសេវាទាំងនេះគឺត្រូវបានអនុវត្តជាចម្បងចំពោះផលិតផលកែច្នៃដែលក្នុងនោះផ្នែកអថេរត្រូវបានអនុវត្តចំពោះវត្ថុធាតុដើម ឬធាតុផ្សំក្នុងផលិតផលសម្រេច។ វាអាចហៅថាការទូទាត់សង (compensatory element)។

*ឧទាហរណ៍៖ អត្រាពន្ធលើស្ករគ្រាប់ត្រូវបានកំណត់ "២៥% បូកនឹង ២៥ដុល្លារសម្រាប់សមាសភាគស្កររួមផ្សំក្នុងមួយគីឡូក្រាម ដកតម្លៃស្ករក្នុងមួយគីឡូក្រាម"។*

---

[5] វិធានការទាំងនេះត្រូវបានហាមឃាត់ដោយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ ក្រោមកិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការទម្លាក់តម្លៃ និងការឧបត្ថម្ភធន និងវិធានការពន្ធប៉ះប៉ូវ ប៉ុន្តែវិធានការដែលមានទម្រង់ជាការអនុវត្តលើតម្លៃត្រូវបានអនុញ្ញាតក្នុងលក្ខខណ្ឌជាក់លាក់។ សូមមើល D13 និង D23 សម្រាប់ឧទាហរណ៍។

[6] វិធានការណ៍នេះត្រូវបានហាមឃាត់ដោយកិច្ចព្រមព្រៀង WTO លើវិស័យកសិកម្ម មាត្រា៤។

**F39 ថ្លៃសេវាអថេរផ្សេងទៀត ក្រៅពីវិធានការខាងលើ**

F4 ពន្ធបន្ថែមលើពន្ធគយ

ការដាក់ពន្ធទៅលើផលិតផលនាំចូលសម្រាប់គោលបំណងជាក់លាក់ណាមួយបន្ថែមពីលើពន្ធគយ ដើម្បីបង្កើនចំណូលសារពើពន្ធ ឬការពារឧស្សាហកម្មក្នុងស្រុក។

***ឧទាហរណ៍÷*** *ពន្ធបន្ថែមលើពន្ធគយ, ការទូទាត់ពន្ធបន្ថែមលើទំនិញដែលបានគិតពន្ធរួចហើយ ឬពន្ធបន្ថែមផ្សេងទៀត។*

F5 ពន្ធតាមរដូវ

ពន្ធត្រូវបានអនុវត្តនៅពេលវេលាជាក់លាក់ក្នុងឆ្នាំ ហើយជាធម្មតាវាទាក់ទងនឹងផលិតផលកសិកម្ម។

***ឧទាហរណ៍÷*** *ការនាំចូលភេសជ្ជៈធ្វើពីផ្លែ Pear ស្រស់ៗក្នុងចំនួនច្រើន ពីថ្ងៃទី១ សីហា ដល់ថ្ងៃទី៣១ ខែធ្នូ មិនតម្រូវឱ្យទូទាត់ពន្ធ ចំណែកឯខែផ្សេងទៀត ពន្ធតាមរដូវត្រូវបានអនុវត្ត។*

F6 ពន្ធនិងថ្លៃសេវាបន្ថែមពាក់ព័ន្ធនឹងសេវាកម្មផ្តល់ដោយរដ្ឋាភិបាល

ថ្លៃសេវាបន្ថែមដែលត្រូវបានប្រមូលពីទំនិញនាំចូលបន្ថែមពីលើពន្ធគយ និងពន្ធបន្ថែមលើពន្ធគយ និងដែលមិនបានអនុវត្តចំពោះទំនិញក្នុងស្រុក។[7] ពន្ធនិងថ្លៃសេវាបន្ថែមទាំងនេះ រួមមាន÷

**F61 ការត្រួតពិពិត្យផ្ទៃកគយ, ប្រតិបត្តិការគយ, កម្រៃសេវាកម្មគយ**

**F62 ការលើកដាក់ទំនិញ ឬកម្រៃរក្សាទុកទំនិញ**

**F63 ពន្ធលើប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេស**

**F64 ពន្ធលើការបោះត្រា**

**F65 កម្រៃអាជ្ញាប័ណ្ណនាំចូលទំនិញ**

**F66 កម្រៃវិក័យប័ត្រកុងស៊ុល**

**F67 ពន្ធស្ថិតិ**

**F68 ពន្ធលើមធ្យោបាយដឹកជញ្ជូន**

**F69 ថ្លៃសេវាបន្ថែម ក្រៅពីវិធានការខាងលើ**

F7 ពន្ធក្នុងស្រុក និងថ្លៃសេវាលើការនាំចូលទំនិញ

ពន្ធប្រមូលពីការនាំចូលទំនិញដែលបានអនុវត្តចំពោះទំនិញក្នុងស្រុកផងដែរ។[8]

---

[7] គួរកត់សំគាល់ថាមាត្រា VIII នៃ GATT ចែងថាថ្លៃឈ្នួលនិងការគិតថ្លៃផ្សេងៗក្រៅពីពន្ធគយ និងពន្ធក្នុងស្រុក “ត្រូវបានកំណត់ជាចំនួនទឹកប្រាក់ប្រហាក់ប្រហែលនឹងថ្លៃសេវាកម្មដែលត្រូវបានផ្តល់ជូន និងមិនត្រូវបង្ហាញពីការការពារដោយប្រយោលដល់ផលិតផលក្នុងស្រុក ឬការប្រមូលពន្ធលើការនាំចូល ឬការនាំចេញសម្រាប់គោលបំណងសារពើពន្ធ។

[8] មាត្រា ៣ នៃកិច្ចព្រមព្រៀង GATT អនុញ្ញាតឱ្យអនុវត្តពន្ធក្នុងស្រុកចំពោះទំនិញនាំចូល។ ប៉ុន្តែពន្ធទាំងនេះមិនគួរមានកម្រិតខ្ពស់ជាងពន្ធដែលបានអនុវត្តចំពោះផលិតផលក្នុងស្រុកស្រដៀងគ្នាទេ។

**F71 ពន្ធលើផលិតផលប្រើប្រាស់**

ពន្ធលើការលក់ផលិតផលដែលត្រូវបានអនុវត្តជាទូទៅចំពោះផលិតផលទាំងអស់ ឬផលិតផលភាគច្រើន។

***ឧទាហរណ៍÷*** *ពន្ធលើការលក់, ពន្ធលើប្រាក់ចំណូល (ឬពន្ធត្រួតគ្នាលើការលក់), អាករលើតម្លៃបន្ថែម។*

**F72 អាករពិសេស**

ពន្ធដែលបានកំណត់លើប្រភេទទំនិញដែលបានជ្រើសរើស ធម្មតាជាទំនិញប្រណីត ឬទំនិញមិនសំខាន់។ ពន្ធនេះត្រូវបានប្រមូលដាច់ដោយឡែក និងបន្ថែមពីលើពន្ធលើការលក់ទូទៅ។

**F73 ពន្ធនិងថ្លៃសេវាសម្រាប់ប្រភេទទំនិញវេទយិត**

ថ្លៃសេវាដែលរាប់បញ្ចូលនូវថ្លៃសេវាបំភាយឧស្ម័ន, ពន្ធលើទំនិញវេទយិត និងថ្លៃសេវារដ្ឋបាល÷ ថ្លៃសេវាចុងក្រោយគេត្រូវបានប្រមូលដើម្បីទូទាត់នូវការចំណាយនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាល។

***ឧទាហរណ៍÷*** *ថ្លៃសេវាលើការបំភាយឧស្ម័នកាបូនិកលើយានយន្ត។*

**F79 ពន្ធក្នុងស្រុក និងថ្លៃសេវាលើទំនិញនាំចូលផ្សេងទៀត ក្រៅពីវិធានការខាងលើ**

F8 ការកំណត់ពន្ធគយដោយក្រឹត្យ

តម្លៃទំនិញដែលបានកំណត់ដោយក្រឹត្យក្នុងគោលបំណងប្រមូលពន្ធគយនិងថ្លៃសេវាផ្សេងៗទៀត÷ ការអនុវត្តនេះត្រូវបានបង្ហាញជាមធ្យោបាយដើម្បីជៀសវាងការក្លែងបន្លំ ឬដើម្បីការពារឧស្សាហកម្មក្នុងស្រុក។ តម្លៃកំណត់ដោយក្រឹត្យបានផ្លាស់ប្តូរពន្ធ ad valorem ទៅជាពន្ធជាក់លាក់។

***ឧទាហរណ៍÷*** *គេប្រើប្រាស់ពាក្យ " valeur mercuriale" ក្នុងប្រទេសដែលប្រើប្រាស់ភាសាបារាំង។*

F9 វិធានការគ្រប់គ្រងតម្លៃ, មិនបានបញ្ជាក់នៅកន្លែងផ្សេង

G **វិធានការហិរញ្ញវត្ថុ**

វិធានការហិរញ្ញវត្ថុមានគោលបំណងធ្វើនិយតកម្មការប្តូររូបិយប័ណ្ណបរទេសនិងថ្លៃប្តូររូបិយប័ណ្ណបរទេសសម្រាប់ទំនិញនាំចូលនិងកំណត់លក្ខខណ្ឌនៃការទូទាត់ (terms of payment)។ ពួកគេអាចធ្វើឱ្យកើនឡើងនូវថ្លៃទំនិញនាំចូលដូចគ្នានឹងវិធានការពន្ធគយផងដែរ។

G1 តម្រូវការទូទាត់ប្រាក់ជាមុន

តម្រូវការទូទាត់ប្រាក់ជាមុនពាក់ព័ន្ធនឹងតម្លៃនៃប្រតិបត្តិការនាំចូល និង/ឬពន្ធនាំចូល÷ ការទូទាត់ទាំងនេះត្រូវបានធ្វើឡើងនៅពេលដាក់ពាក្យស្នើសុំជាផ្លូវការ ឬនៅពេលចេញអាជ្ញាប័ណ្ណនាំចូលទំនិញ។ ការទូទាត់ទាំងនេះ រួមមាន÷

**G11 ប្រាក់តម្កល់លើការនាំចូលទំនិញជាមុន**

តម្រូវការដែលអ្នកនាំចូលគួរតម្កល់ប្រាក់ដែលគិតជាភាគរយនៃតម្លៃប្រតិបត្តិការនាំចូលមុនពេលទទួលទំនិញ÷ គ្មានការទូទាត់ការប្រាក់ទៅលើប្រាក់តម្កល់នេះទេ។

***ឧទាហរណ៍៖*** *ការតម្រូវឱ្យមានការទូទាត់ ៥០% នៃតម្លៃប្រតិបត្តិការក្នុងរយៈពេល ៣ខែ មុនពេលទំនិញមកដល់កំពង់ផែតាមការរំពឹងទុក។*

**G12 តម្រូវការកម្រិតសាច់ប្រាក់**

តម្រូវការក្នុងការតម្កល់ចំនួនទឹកប្រាក់សរុបនៃតម្លៃប្រតិបត្តិការឬចំនួនទឹកប្រាក់ដែលបានបញ្ជាក់ជារូបិយប័ណ្ណបរទេសក្នុងធនាគារពាណិជ្ជកម្មមុនពេលបើកលិខិតឥណទាន។

***ឧទាហរណ៍៖*** *ការតម្រូវឱ្យតម្កល់ប្រាក់ ១០០% នៃតម្លៃប្រតិបត្តិការនៅធនាគារពាណិជ្ជដែលបានកំណត់។*

**G13 ការទូទាត់ពន្ធគយជាមុន**

តម្រូវការក្នុងការទូទាត់ពន្ធគយទាំងស្រុង ឬដោយផ្នែកជាមុន៖ គ្មានការទូទាត់ការប្រាក់ទៅលើការទូទាត់ជាមុននេះទេ។

***ឧទាហរណ៍៖*** *តម្រូវការក្នុងការទូទាត់ ១០០% នៃពន្ធគយដែលបានប៉ាន់ស្មានក្នុងរយៈ ៣ខែ មុនពេលទំនិញមកដល់កំពង់ផែតាមការរំពឹងទុក។*

**G14 ប្រាក់តម្កល់សងវិញសម្រាប់ប្រភេទផលិតផលវេទយិត**

តម្រូវការក្នុងការទូទាត់ចំនួនប្រាក់តម្កល់ជាក់លាក់ដែលត្រូវបានសងត្រលប់មកវិញនៅពេលដែលផលិតផលប្រើប្រាស់រួច ឬកុងតឺន័ររបស់វាត្រូវបានបញ្ជូនត្រលប់មកប្រព័ន្ធប្រមូលវិញ។

***ឧទាហរណ៍៖*** *ការតម្រូវឱ្យតម្កល់សាច់ប្រាក់ ១០០ ដុល្លារ សម្រាប់ទូទឹកកកនីមួយៗ ហើយប្រាក់តម្កល់នេះនឹងត្រូវបានសងត្រលប់មកវិញនៅពេលទូទឹកកកត្រូវបានយកមកកែច្នៃបន្ទាប់ពីប្រើប្រាស់រួច។*

**G19 តម្រូវការក្នុងការទូទាត់ប្រាក់ជាមុនផ្សេងទៀត ក្រៅពីវិធានការខាងលើ**

G2 អត្រាប្តូរប្រាក់ច្រើន

ការផ្លាស់ប្តូរអត្រាប្តូរប្រាក់សម្រាប់ទំនិញនាំចូលអាស្រ័យលើប្រភេទផលិតផល៖ ជាធម្មតាអត្រាផ្លូវការត្រូវបានរក្សាទុកសម្រាប់ទំនិញសំខាន់ៗ ខណៈពេលដែលទំនិញផ្សេងទៀតត្រូវទូទាត់តាមអត្រាពាណិជ្ជកម្ម ឬពេលខ្លះដោយការទិញរូបិយប័ណ្ណបរទេសតាមរយៈការដេញថ្លៃ។[9]

ឧទាហរណ៍៖ មានតែការទូទាត់ថ្លៃអាហារសម្រាប់ទារក និងការនាំចូលចំណីអាហារប៉ុណ្ណោះដែលត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការ។

---

[9] ការប្រើប្រាស់អត្រាប្តូរប្រាក់ច្រើនត្រូវបានហាមឃាត់ជាផ្លូវការដោយ GATT ១៩៩៤ ។

UNCTAD NTM-KH.indd 34 11/23/2021 3:39:35 PM

G3 បទប្បញ្ញត្តិពាក់ព័ន្ធនឹងការបែងចែកការប្តូររូបិយប័ណ្ណបរទេសផ្លូវការ

**G31 ការហាមឃាត់ការបែងចែកការប្តូររូបិយប័ណ្ណបរទេស**

គ្មានការបែងចែកការប្តូររូបិយប័ណ្ណបរទេសផ្លូវការសម្រាប់ការទូទាត់លើទំនិញនាំចូលឡើយ។

***ឧទាហរណ៍÷*** *ការប្តូររូបិយប័ណ្ណបរទេសមិនត្រូវបានបែងចែកសម្រាប់ការនាំចូលផលិតផលប្រណីត ដូចជាយានយន្តទូរទស្សន៍ គ្រឿងអលង្ការ។ល។*

**G32 ការអនុញ្ញាតពីធនាគារ**

តម្រូវការក្នុងការទទួលបានការអនុញ្ញាតលើការនាំចូលពិសេសពីធនាគារកណ្តាល។

***ឧទាហរណ៍÷*** *សម្រាប់ការនាំចូលយានយន្ត លិខិតអនុញ្ញាតចេញដោយធនាគារកណ្តាលត្រូវបានទាមទារបន្ថែមពីលើអាជ្ញាប័ណ្ណនាំចូលទំនិញ។*

**G33 ការអនុញ្ញាតពាក់ព័ន្ធនឹងការប្តូររូបិយប័ណ្ណបរទេសក្រៅផ្លូវការ**

អាជ្ញាប័ណ្ណត្រូវបានផ្តល់ឱ្យលុះត្រាតែការប្តូររូបិយប័ណ្ណក្រៅផ្លូវការត្រូវបានប្រើសម្រាប់ការទូទាត់លើទំនិញនាំចូល។

**G331 ការប្តូររូបិយប័ណ្ណបរទេសខាងក្រៅ**

អាជ្ញាប័ណ្ណត្រូវបានផ្តល់ឱ្យសម្រាប់តែទំនិញនាំចូលទាក់ទងនឹងគម្រោងជំនួយបច្ចេកទេសប៉ុណ្ណោះ និងប្រភពផ្សេងទៀតនៃការប្តូររូបិយប័ណ្ណបរទេសខាងក្រៅ។

***ឧទាហរណ៍÷*** *ការនាំចូលសំភារៈសំណង់ត្រូវបានអនុញ្ញាតលុះត្រាតែការទូទាត់ត្រូវបានធ្វើឡើងតាមរយៈមូលនិធិនៃការវិនិយោគផ្ទាល់ពីបរទេស។*

**G332 រូបិយប័ណ្ណបរទេសរបស់អ្នកនាំចូល**

អាជ្ញាប័ណ្ណត្រូវបានផ្តល់ឱ្យប្រសិនបើអ្នកនាំចូលមានរូបិយប័ណ្ណបរទេសនៅធនាគារបរទេស។

***ឧទាហរណ៍÷*** *ការនាំចូលវត្ថុធាតុដើមវាយនភ័ណ្ឌត្រូវបានអនុញ្ញាតប្រសិនបើអ្នកនាំចូលអាចទូទាត់ដោយផ្ទាល់ទៅអ្នកនាំចេញដោយប្រើប្រាស់រូបិយប័ណ្ណបរទេសដែលទទួលបានពីសកម្មភាពនាំចេញទៅក្រៅប្រទេស។*

**G339 អាជ្ញាប័ណ្ណពាក់ព័ន្ធនឹងការប្តូររូបិយប័ណ្ណបរទេសក្រៅផ្លូវការផ្សេងទៀត ក្រៅពីវិធានការខាងលើ**

**G39 បទប្បញ្ញត្តិពាក់ព័ន្ធនឹងការបែងចែកការប្តូររូបិយប័ណ្ណបរទេសផ្លូវការ ក្រៅពីវិធានការខាងលើ**

G4 បទប្បញ្ញត្តិពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការទូទាត់ប្រាក់សម្រាប់ទំនិញនាំចូល

បទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌនៃការទូទាត់ប្រាក់លើទំនិញនាំចូលនិងការទទួលបាននិងការប្រើប្រាស់ឥណទាន (បរទេសឬក្នុងស្រុក) ដើម្បីធ្វើការទូទាត់ប្រាក់លើទំនិញនាំចូល។

***ឧទាហរណ៍÷*** *មិនលើសពី ៥០% នៃតំលៃប្រតិបត្តិការដែលអាចត្រូវបានទូទាត់មុនពេលទំនិញមកដល់កំពង់ផែ។*

G9 វិធានការហិរញ្ញវត្ថុផ្សេងទៀត ក្រៅពីវិធានការខាងលើ

H **វិធានការដែលជះឥទ្ធិពលដល់ការប្រកួតប្រជែង**

វិធានការក្នុងការផ្តល់នូវការអនុគ្រោះផ្តាច់មុខឬពិសេស ឬផ្តល់នូវបុព្វសិទ្ធិដល់ក្រុមប្រតិបត្តិករសេដ្ឋកិច្ចមួយឬច្រើន។

H1 សហគ្រាសពាណិជ្ជកម្មរដ្ឋ, សម្រាប់ការនាំចូល, បណ្តាញនៃការនាំចូលដែលបានជ្រើសរើសផ្សេងទៀត

**H11 សហគ្រាសពាណិជ្ជកម្មរដ្ឋ, សម្រាប់ការនាំចូល**

សហគ្រាស (ទោះបីជាកម្មសិទ្ធិរបស់រដ្ឋឬគ្រប់គ្រងដោយរដ្ឋ) ដែលមានសិទ្ធិពិសេសនិងបុព្វសិទ្ធិ ហើយសិទ្ធិនេះមិនត្រូវបានប្រគល់ឱ្យអង្គភាពផ្សេងទៀត បានជះឥទ្ធិពលដល់កម្រិតឬទិសដៅនៃការនាំចូលផលិតផលជាក់លាក់ណាមួយតាមរយៈការទិញនិងការលក់របស់ពួកគេ (សូមមើល P21)។ ឧទាហរណ៍÷ ក្រុមប្រឹក្សាទីផ្សារកំណត់ដោយច្បាប់ដែលមានសិទ្ធិផ្តាច់មុខដើម្បីគ្រប់គ្រងការនាំចូលប្រភេទធញ្ញជាតិជាក់លាក់ណាមួយ, ភ្នាក់ងារដែលមានសិទ្ធិផ្តាច់មុខក្នុងការចែកចាយប្រេងឥន្ធនៈ, ជាភ្នាក់ងារនាំចូលទំនិញតែមួយគត់ឬការនាំចូលទំនិញដែលបានរក្សាទុកសម្រាប់អ្នកនាំចូលជាក់លាក់ទាក់ទងនឹងប្រភេទនៃទំនិញណាមួយ។

**H19 បណ្តាញនៃការនាំចូលដែលត្រូវបានជ្រើសរើសផ្សេងទៀត ក្រៅពីវិធានការខាងលើ**

H2 កាតព្វកិច្ចក្នុងការប្រើប្រាស់សេវាកម្មជាតិ

**H21 កាតព្វកិច្ចក្នុងការប្រើប្រាស់ការធានារ៉ាប់រងជាតិ**

តម្រូវការដែលទំនិញនាំចូលត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងជាតិ។

**H22 កាតព្វកិច្ចក្នុងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនជាតិ**

តម្រូវការដែលទំនិញនាំចូលត្រូវបានដឹកជញ្ជូនដោយក្រុមហ៊ុនដឹកជញ្ជូនជាតិ។

**H29 កាតព្វកិច្ចក្នុងការប្រើប្រាស់សេវាកម្មជាតិ, មិនបានបញ្ជាក់នៅកន្លែងផ្សេង**

H9 វិធានការដែលជះឥទ្ធិពលលើការប្រកួតប្រជែង ក្រៅពីវិធានការខាងលើ

I **វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម** [10,11]

I1 វិធានការសមាសធាតុក្នុងស្រុក

តម្រូវការក្នុងការទិញឬប្រើប្រាស់ត្រឹមកម្រិតអតិបរមាជាក់លាក់ ឬប្រភេទនៃផលិតផលដែលបានផលិតឬមានប្រភពក្នុងស្រុក ឬការដាក់កម្រិតទៅលើការទិញ ឬការប្រើប្រាស់ផលិតផលនាំចូលផ្អែកលើបរិមាណឬតម្លៃនៃការនាំចេញផលិតផលក្នុងស្រុក។

---

[10] ផ្អែកលើការលើកលែងជាក់លាក់, វិធានការដែលបានរៀបរាប់នៅក្នុង I1-I2 មិនអនុលោមតាមកិច្ចព្រមព្រៀង TRIMs ទេ (កាតព្វកិច្ចនៃប្រព្រឹត្តិកម្មជាតិក្រោមមាត្រា III និងការលុបបំបាត់ចោលទូទៅ QRs ក្រោមមាត្រា XI នៃ GATT ឆ្នាំ ១៩៩៤) ។ សូមមើលបញ្ជីពន្យល់ដែលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង TRIMs ។

[11] វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្មក្រោមរូបភាពជាការរឹតត្បិតការនាំចេញត្រូវបានបញ្ចូលក្នុងផ្នែក P1។

***ឧទាហរណ៍÷*** *ក្នុងការផលិតរថយន្ត, សមាសធាតុដែលផលិតក្នុងស្រុកត្រូវមានយ៉ាងហោចណាស់ ៥០% នៃតម្លៃនៃសមាសធាតុដែលបានប្រើប្រាស់។*

I2 វិធានការតុល្យភាពពាណិជ្ជកម្ម

ការដាក់កម្រិតលើការនាំចូលផលិតផលដែលបានប្រើនៅក្នុងឬទាក់ទងទៅនឹងផលិតកម្មក្នុងស្រុក ដែលរាប់បញ្ចូល បរិមាណផលិតផលក្នុងស្រុកដែលបាននាំចេញ ឬការដាក់កម្រិតការប្រើប្រាស់រូបិយប័ណ្ណបរទេសសម្រាប់ការនាំចូល ផ្អែកលើលំហូរនៃរូបិយប័ណ្ណបរទេសដែលទទួលបានពីសហគ្រាសពាក់ព័ន្ធ។

***ឧទាហរណ៍÷*** *ក្រុមហ៊ុនអាចនាំចូលសំភារៈនិងផលិតផលផ្សេងទៀតត្រឹម ៨០% នៃប្រាក់ចំណូលនាំចេញរបស់ខ្លួនកាលពីឆ្នាំកន្លងមក។*

I9 វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម ក្រៅពីវិធានការខាងលើ

J **ការដាក់កម្រិតលើការចែកចាយទំនិញ**

ការចែកចាយទំនិញនៅក្នុងប្រទេសនាំចូលអាចត្រូវបានដាក់កម្រិត។ ការចែកចាយទំនិញអាចត្រូវបានគ្រប់គ្រងតាមរយៈតម្រូវការអាជ្ញាប័ណ្ណឬវិញ្ញាបនបត្របន្ថែម។[12]

J1 ការដាក់កម្រិតផ្អែកភូមិសាស្ត្រ

ការដាក់កម្រិតលើការលក់ទំនិញទៅតំបន់ជាក់លាក់មួយចំនួននៅក្នុងប្រទេសនាំចូល។

***ឧទាហរណ៍÷*** *ភេសជ្ជៈដែលត្រូវបាននាំចូលអាចត្រូវបានលក់តែនៅក្នុងទីក្រុងដែលមានទីតាំងដែលអាចធ្វើការកែច្នៃកំប៉ុងឡើងវិញប៉ុណ្ណោះ។*

J2 ការដាក់កម្រិតលើអ្នកលក់បន្ត

ការដាក់កម្រិតលើការលក់ផលិតផលនាំចូលដោយអ្នកលក់រាយដែលបានកំណត់។

***ឧទាហរណ៍÷*** *អ្នកនាំចេញយានយន្តត្រូវបង្កើតហាងលក់យានយន្តផ្ទាល់ខ្លួន ព្រោះពាណិជ្ជករផ្នែករថយន្តដែលមានស្រាប់នៅក្នុងប្រទេសគោលដៅ គឺជាអ្នកផលិតរថយន្តនៅក្នុងប្រទេសនោះ។*

K **ការដាក់កម្រិតលើសេវាកម្មក្រោយពេលលក់**

វិធានការដែលដាក់កម្រិតលើអ្នកផលិតទំនិញនាំចេញក្នុងការផ្តល់សេវាកម្មក្រោយពេលលក់នៅក្នុងប្រទេសនាំចូល។

***ឧទាហរណ៍÷*** *សេវាកម្មក្រោយពេលលក់ទូរទស្សន៍ដែលបាននាំចេញ ត្រូវតែផ្តល់ឱ្យដោយក្រុមហ៊ុនសេវាកម្មក្នុងស្រុកនៃប្រទេសនាំចូល។*

---

[12] ការរឹតត្បិតទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងនិយតកម្មនៃសេវាកម្មចែកចាយទំនិញ។

L **ការឧបត្ថម្ភធន (មិនរាប់បញ្ចូលការឧបត្ថម្ភធនលើការនាំចេញទំនិញក្រោម** P7)

ការផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលឬស្ថាប័នសាធារណៈ ឬតាមរយៈការផ្តល់ភារកិច្ចឬការណែនាំដល់ស្ថាប័នឯកជនដោយរដ្ឋាភិបាល (ការផ្ទេរមូលនិធិដោយផ្ទាល់ឬអាចនឹងដោយផ្ទាល់ប្រសិនបើលក្ខខណ្ឌចាំបាច់ត្រូវបានបំពេញ÷ ឧទាហរណ៍ អំណោយ, ប្រាក់កម្ចី, ការបញ្ចូលភាគហ៊ុន (equity infusion), ការធានា, ចំណូលរដ្ឋាភិបាលដែលមិនបានប្រមូល, ការផ្តល់ទំនិញឬសេវាកម្មឬការទិញទំនិញ, ការទូទាត់លើយន្តការផ្តល់ថវិកា) ឬការគាំទ្រប្រាក់ចំណូលឬតម្លៃ ដែលផ្តល់ផលប្រយោជន៍និងមានភាពជាក់លាក់ (ចំពោះសហគ្រាសមួយឬឧស្សាហកម្មមួយឬក្រុមទាំងនោះឬត្រូវបានដាក់កម្រិតចំពោះតែតំបន់ភូមិសាស្ត្រដែលបានកំណត់)។

***ឧទាហរណ៍÷ រ**ដ្ឋាភិបាលផ្តល់សាច់ប្រាក់មួយផងដល់អ្នកផលិតសារធាតុគីមីដើម្បីផ្លាស់ប្តូរឧបករណ៍ផលិតកម្មចាស់។*

***សម្គាល់÷ ផ្នែកនេះនឹងត្រូវបានបែងចែកបន្តទៀតបន្ទាប់ពីការសិក្សាបន្ថែមលើប្រធានបទនេះ។***

M **ការដាក់កម្រិតលើលទ្ធកម្មរដ្ឋាភិបាល**

វិធានការគ្រប់គ្រងការទិញទំនិញដោយភ្នាក់ងាររដ្ឋាភិបាល ជាទូទៅដោយជ្រើសរើសអ្នកផ្គត់ផ្គង់ជាតិ។

***ឧទាហរណ៍÷** ការិយាល័យរដ្ឋាភិបាលមានអ្នកផ្គត់ផ្គង់តម្រូវការឧបករណ៍ការិយាល័យរបស់ខ្លួន ទោះបីមានតម្លៃខ្ពស់ជាងអ្នកផ្គត់ផ្គង់បរទេសស្រដៀងគ្នាក៏ដោយ។*

N **កម្មសិទ្ធិបញ្ញា**

វិធានការទាក់ទងនឹងកម្មសិទ្ធិបញ្ញាក្នុងពាណិជ្ជកម្ម÷ ច្បាប់កម្មសិទ្ធិបញ្ញាគ្របដណ្តប់លើប្រកាសនីយបត្រកម្ម (patents), ម៉ាក (trademarks), គំនូរឧស្សាហកម្ម (industrial designs), គំនូរបង្ហាញនៃសៀគ្វីបង្រួម (layout designs of integrated circuits), សិទ្ធិអ្នកនិពន្ធ (copyright), ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (geographical indications), ការសម្ងាត់ពាណិជ្ជកម្ម (trade secrets)។

***ឧទាហរណ៍÷** សម្លៀកបំពាក់ដែលមិនមានការអនុញ្ញាតឱ្យប្រើប្រាស់ពាណិជ្ជសញ្ញាត្រូវបានលក់ក្នុងតម្លៃទាបជាងតម្លៃផលិតផលពិតប្រាកដ។*

O **វិធានដើមកំណើត**

វិធានដើមកំណើតគ្របដណ្តប់លើច្បាប់ បទប្បញ្ញត្តិ និងការកំណត់នីតិវិធីរដ្ឋបាលលើការអនុវត្តទូទៅរបស់រដ្ឋាភិបាលនៃប្រទេសនាំចូលក្នុងគោលបំណងកំណត់ប្រភពដើមនៃទំនិញ។ វិធានដើមកំណើតមានសារៈសំខាន់ក្នុងការអនុវត្តឧបករណ៍គោលនយោបាយពាណិជ្ជកម្ម ដូចជាការប្រឆាំងនឹងការលក់បង្ខូចថ្លៃនិងពន្ធប៉ះប៉ូវ (antidumping and countervailing duties) សញ្ញាបញ្ជាក់ដើមកំណើត (origin marking) និងវិធានការការពារ (safeguard measures)។

***ឧទាហរណ៍÷*** *ផលិតផលគ្រឿងម៉ាស៊ីនផលិតនៅក្នុងប្រទេសមួយពិបាកក្នុងការបំពេញតាមវិធានដើមកំណើតដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់អត្រាពន្ធកាត់បន្ថយនៃប្រទេសនាំចូលព្រោះផ្នែកនិងវត្ថុធាតុដើមមានដើមកំណើតនៅប្រទេសផ្សេងៗគ្នា។*

P **វិធានការពាក់ព័ន្ធនឹងការនាំចេញទំនិញ**

វិធានការពាក់ព័ន្ធនឹងការនាំចេញគឺជាវិធានការដែលត្រូវបានអនុវត្តដោយរដ្ឋាភិបាលនៃប្រទេសនាំចេញលើទំនិញនាំចេញ។

P1 អាជ្ញាប័ណ្ណនាំចេញទំនិញ, កូតានាំចេញទំនិញ, ការហាមឃាត់ការនាំចេញទំនិញ, និងការដាក់កម្រិតលើបរិមាណនាំចេញទំនិញផ្សេងៗទៀត13

ការដាក់កម្រិតលើបរិមាណនៃទំនិញដែលបាននាំចេញទៅប្រទេសជាក់លាក់មួយឬច្រើនដោយរដ្ឋាភិបាលនៃប្រទេសនាំចេញព្រោះហេតុផលមួយចំនួន ដូចជាការខ្វះខាតទំនិញក្នុងទីផ្សារក្នុងស្រុក, ការគ្រប់គ្រងតម្លៃក្នុងស្រុក, ការជៀសវាងវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃឬហេតុផលនយោបាយ។[14]

**P11 ការហាមឃាត់ការនាំចេញទំនិញ**

ការហាមឃាត់ការនាំចេញទំនិញជាក់លាក់មួយចំនួន។

***ឧទាហរណ៍÷*** *ការនាំចេញពោតត្រូវបានហាមឃាត់ព្រោះកង្វះខាតពោតក្នុងទីផ្សារក្នុងស្រុក។*

**P12 កូតានាំចេញទំនិញ**

កូតាដែលកម្រិតតម្លៃឬបរិមាណនៃការនាំចេញទំនិញ។

***ឧទាហរណ៍÷*** *កូតានៃការនាំចេញសាច់គោត្រូវបានបង្កើតឡើងដើម្បីធានាឱ្យបាននូវការផ្គត់ផ្គង់គ្រប់គ្រាន់ក្នុងទីផ្សារក្នុងស្រុក។*

**P13 តម្រូវការអាជ្ញាប័ណ្ណឬការអនុញ្ញាតក្នុងការនាំចេញទំនិញ**

តម្រូវការក្នុងការទទួលបាននូវអាជ្ញាប័ណ្ណឬការអនុញ្ញាតពីរដ្ឋាភិបាលនៃប្រទេសនាំចេញដើម្បីនាំចេញផលិតផល។

***ឧទាហរណ៍÷*** *ការនាំចេញរ៉ែពេជ្រគឺតម្រូវឱ្យស្នើសុំអាជ្ញាប័ណ្ណពីក្រសួង។*

**P14 តម្រូវការចុះបញ្ជីការនាំចេញទំនិញ**

តម្រូវការក្នុងការចុះបញ្ជីផលិតផលមុនពេលនាំចេញ (សម្រាប់គោលបំណងតាមដាន)។

***ឧទាហរណ៍÷*** *ផលិតផលឱសថតម្រូវឱ្យចុះបញ្ជីជាចាំបាច់មុនពេលនាំចេញ។*

**P19 ការដាក់កម្រិតលើបរិមាណនាំចេញទំនិញផ្សេងៗទៀត ក្រៅពីវិធានការខាងលើ**

P2 សហគ្រាសពាណិជ្ជកម្មរដ្ឋ, សម្រាប់ការនាំចេញ, បណ្តាញនៃការនាំចេញដែលបានជ្រើសរើសផ្សេងទៀត

---

[13] វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្មក្រោមរូបភាពជាការរឹតត្បិតលើការនាំចេញទំនិញត្រូវបានរាប់បញ្ចូលទៅក្នុងផ្នែកនេះ។

[14] វិធានការទាំងអស់នេះត្រូវបានហាមឃាត់ជាផ្លូវការដោយ GATT ១៩៩៤។ ប៉ុន្តែវិធានការទាំងអស់នេះអាចនឹងត្រូវបានអនុវត្តក្នុងស្ថានភាពជាក់លាក់ណាមួយដែលបានកំណត់ក្នុងមាត្រា XI នៃ GATT ១៩៩៤។

**P21 សហគ្រាសពាណិជ្ជកម្មរដ្ឋ សម្រាប់ការនាំចេញ**

សហគ្រាស (ទោះបីជាកម្មសិទ្ធិរបស់រដ្ឋឬគ្រប់គ្រងដោយរដ្ឋ) ដែលមានសិទ្ធិពិសេសនិងបុព្វសិទ្ធិ ហើយសិទ្ធិនេះមិនត្រូវបានប្រគល់ឱ្យអង្គភាពផ្សេងទៀត បានជះឥទ្ធិពលដល់កម្រិតឬទិសដៅនៃការនាំចេញផលិតផលជាក់លាក់ណាមួយតាមរយៈការទិញនិងការលក់របស់ពួកគេ (សូមមើល H1)។

***ឧទាហរណ៍÷*** *ក្រុមប្រឹក្សាភិបាលនាំចេញទំនិញផ្តាច់មុខមួយបានទាញយកអត្ថប្រយោជន៍ពីលក្ខខណ្ឌនៃការលក់នៅបរទេស។ ក្រុមប្រឹក្សាភិបាលទីផ្សារមួយបានជំរុញដល់ការនាំចេញជំនួសមុខឱ្យកសិករខ្នាតតូចជាច្រើននាក់។*

**P29 បណ្តាញនៃការនាំចេញទំនិញដែលបានជ្រើសរើសផ្សេងៗទៀត ក្រៅពីវិធានការចាងលើ**

P3 វិធានការគ្រប់គ្រងតម្លៃទំនិញនាំចេញ

វិធានការដែលបានអនុវត្តដើម្បីគ្រប់គ្រងតម្លៃនៃទំនិញនាំចេញ។

***ឧទាហរណ៍÷*** *តម្លៃខុសគ្នាត្រូវបានកំណត់ចំពោះទំនិញដែលបាននាំចេញនិងទំនិញដូចគ្នាដែលបានលក់នៅក្នុងទីផ្សារក្នុងស្រុក (គម្រោងកំណត់តម្លៃពីរ)។*

P4 វិធានការលើការនាំចេញឡើងវិញ

វិធានការដែលបានអនុវត្តដោយរដ្ឋាភិបាលនៃប្រទេសនាំចេញលើការទំនិញនាំចេញដែលត្រូវបាននាំចូលពីបរទេសពីដំបូងឡើយ។

***ឧទាហរណ៍÷*** *ការនាំចេញស្រានិងស្រាខ្លាំងត្រលប់ទៅកាន់ប្រទេសផលិតវិញត្រូវបានហាមឃាត់។ ការអនុវត្តនេះគឺជារឿងធម្មតានៅក្នុងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដើម្បីជៀសវាងការដាក់ពន្ធក្នុងប្រទេសផលិត។*

P5 ការគិតថ្លៃនិងពន្ធលើទំនិញនាំចេញ

ពន្ធដែលប្រមូលបានដោយរដ្ឋាភិបាលនៃប្រទេសនាំចេញលើទំនិញនាំចេញ។ ពន្ធទាំងនេះអាចត្រូវបានកំណត់ជាអត្រាជាក់លាក់ឬពន្ធ ad volorem។

***ឧទាហរណ៍÷*** *ពន្ធនាំចេញលើប្រេងឆៅត្រូវបានប្រមូលសម្រាប់គោលបំណងប្រាក់ចំណូល។*

P6 វិធានការបច្ចេកទេសលើការនាំចេញទំនិញ

បទប្បញ្ញត្តិនៃការនាំចេញទំនិញសំដៅទៅលើលក្ខណៈបច្ចេកទេសនៃផលិតផលនិងប្រព័ន្ធវាយតម្លៃអនុលោមភាព (conformity assessment systems)÷

**P61 តម្រូវការត្រួតពិនិត្យ**

ការត្រួតពិនិត្យលើគុណភាពឬលក្ខណៈផ្សេងទៀតនៃផលិតផលសម្រាប់ការនាំចេញ។

***ឧទាហរណ៍÷*** *ការនាំចេញផលិតផលអាហារកែច្នៃត្រូវតែបានត្រួតពិនិត្យសម្រាប់លក្ខខណ្ឌអនាម័យ។*

**P62 វិញ្ញាបនបត្រដែលទាមទារដោយប្រទេសនាំចេញ**

ការតម្រូវឱ្យទទួលបាននូវវិញ្ញាបនបត្រអនាម័យ ភូតគាមអនាម័យ (sanitary, phytosanitary) ឬវិញ្ញាបនបត្រផ្សេងទៀតមុនពេលទំនិញត្រូវបាននាំចេញ។

***ឧទាហរណ៍÷*** *ការនាំចេញសត្វមានជីវិតត្រូវមានវិញ្ញាបនបត្របញ្ជាក់ពីសុខភាព។*

**P69 វិធានការបច្ចេកទេសលើការនាំចេញទំនិញ ក្រៅពីវិធានការខាងលើ**

P7 ការឧបត្ថម្ភធនលើការនាំចេញទំនិញ

ការផ្តល់ហិរញ្ញប្បទានដោយរដ្ឋាភិបាលឬស្ថាប័នសាធារណៈ ឬតាមរយៈការផ្តល់ភារកិច្ចឬការណែនាំដល់ស្ថាប័នឯកជនដោយរដ្ឋាភិបាល (ការផ្ទេរមូលនិធិដោយផ្ទាល់ឬអាចនឹងដោយផ្ទាល់ប្រសិនបើលក្ខខណ្ឌចាំបាច់ត្រូវបានបំពេញ÷ ឧទាហរណ៍ អំណោយ, ប្រាក់កម្ចី, ការបញ្ចូលភាគហ៊ុន (equity infusion), ការធានា, ចំណូលរដ្ឋាភិបាលដែលមិនបានប្រមូល, ការផ្តល់ទំនិញឬសេវាកម្មឬការទិញទំនិញ, ការទូទាត់លើយន្តការផ្តល់ថវិកា) ឬការគាំទ្រប្រាក់ចំណូលឬតម្លៃ ដែលផ្តល់ផលប្រយោជន៍និងអាស្រ័យលើច្បាប់ឬការពិតពាក់ព័ន្ធនឹងប្រតិបត្តិការនាំចេញ (ទោះបីជាលក្ខខណ្ឌតែមួយគត់ឬជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌមួយចំនួន) រួមទាំងវិធានការដែលបង្ហាញក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀងស្តីពីការធ្វើឧបត្ថម្ភធននិងវិធានការប៉ះប៉ូវនិងវិធានការដែលបានរៀបរាប់នៅក្នុងកិច្ចព្រមព្រៀងស្តីពីកសិកម្ម។

***ឧទាហរណ៍÷*** *ក្រុមហ៊ុនកម្មន្តសាលទាំងអស់នៅក្នុងប្រទេស A ត្រូវបានលើកលែងពន្ធលើប្រាក់ចំណេញចំពោះប្រាក់ចំណេញដែលទទួលបានពីការនាំចេញរបស់ពួកគេ។*

P8 ឥណទានលើការនាំចេញទំនិញ

P9 វិធានការលើការនាំចេញទំនិញផ្សេងទៀត ក្រៅពីវិធានការខាងលើ

UNCTAD NTM-KH.indd 42 11/23/2021 3:39:37 PM